# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៦ ខែមីនា លេខ ៣

ព.ស. ២៤៩៧ – គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា — បញ្ជីរឿង — ទំព័រ

— សុខកថា .................. ព្រះមហា សុខ–វន់ ....... ១៦៣
— វិម្មិកប្បញ្ហា .................. ព្រះមហា ប័ន្ធ–ហុង ...... ១៧២

ផ្នែកអក្សរសាស្ត្រ

— រឿងព្រេងបួននិទាន ........... ឃុនបណ្ណានុរក្សប៊ូ–ប៊ូ ...... ១៨២
— ការបណ្ដុះនិស្ស័យ (តមក) ........ ព្រះមហាឧត្ដមវិជ្ជា ប៊ុង–ប៉ម ... ១៨៩
— រឿងសាមកុក (តមក) ........... ឧកញ៉ា នូ–កន .......... ១៩៨
— ទាលៈនិងទមយន្ដី (តមក) ........ អ្នកស្រី ស៊្រុន–សារីយ៉ាន់ .... ២១០
— ដំណើរអស្ចារ្យនៃលោកភីស្ហូបីយូយេ (តមក) .................... លោកភ៉យ–ប៊ុក ......... ២១៩
— ដំណឹងតាមខ្យល់ក្នុងកន្ដារៈ (តមក) .... លោកដេង–ជ្រីវ ......... ២២៥

កំណត់នីងប្រវត្តិការណ៍

— សុន្ទរកថាថ្លែងក្នុងពិធីអនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១០ ........ ឯកឧត្ដម សម–ញាណ..... ២៣៥

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

PARTIE RELIGIEUSE:


— Sukhakatha . . . . . . . . *Brah Maha* SOK-VON . . . . . 163

— Vammikappanha . . . . . . *Brah Maha* CHANN-HONG . . . 172


PARTIE LITTERAIRE:


— Les quatre légendes . . . . . M. BOU-PO . . . . . . . . . . 182

— Education morale (suite) . . . *Brah Maha* PEUNG-PAM . . . . 189

— Histoire de SAMKOK (suite) . *Oknha* NOU-KAN . . . . . . . 198

— Nala et Damayanti (suite) . . *Mme* SRIN-SARIS-YANN . . . . 210

— Le voyage extraordinaire de Vasiobioyé (suite) . . . . . . M. RAY-BUC . . . . . . . . . 219

— Le souffle du désert (suite) . M. PHENG CHRIV . . . . . . . 225


NOTES ET CHRONIQUES:


— Allocution de S. E. le Ministre des Cultes à la 10 ème Assemblée Religieuse . . . . . . S. E. SAM-NHEAN . . . . . . 235


Prix d'abonnement annuel (comprenant 12 numéros) 200$00

## សុខកថា

# ព្រះមហា សុខ-រិទ្ធ និស្សិតសាលាបាលីជាន់ខ្ពស់

រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយសេចក្ដីគោរព) ។*

*លំដាប់នេះ អាត្មាភាពនឹងសំដែងអំពីកំណើតនៃសេចក្ដីសុខ ជាសង្ខេបតាមសមគួរដល់កាលវេលា ដូចមានសេចក្ដីតទៅនេះ ៗ*

សុខោ ពុទ្ធានមុប្បាទោ *"ការកើតឡើង នៃព្រះពុទ្ធទាំងឡាយ ជាហេតុនាំឲ្យកើតសេចក្ដីសុខ" ៗ*

*អធិប្បាយថា: ក្នុងកាលដែលមានព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងឡើង, សត្វមានចំនួនច្រើនរាប់មិនអស់ តែងបានជួបប្រទះនូវប្រយោជន៍នឹងសេចក្ដីសុខស្ងប់ដ៏ក្រៃលែង ៗ ព្រោះព្រះសព្វញ្ញុពុទ្ធទ្រង់ឧបត្តិឡើង ទ្រង់ប្រកបដោយសិរីសម្បត្តិដ៏ខ្ពង់ខ្ពស់គួរស្ងើច ជាទីបូជារបស់ពួកជនហើយបរិបូណ៌ដោយចំណេះវិជ្ជាគ្រប់យ៉ាង ព្រមទាំងមានព្រះទ័យពេញប្រៀបដោយសេចក្ដីករុណា អាណិតអាសូរពួកសត្វលោកក្នុងត្រៃភព*

ឥតរើសមុខ ។ ដោយពិត, ព្រះបរមគ្រូដែលទ្រង់បានជួបប្រទះនឹងសេចក្ដីសុខក្រេមខ្ពង់ខ្ពស់ផុតចំណោមមនុស្ស ដោយគោត្រត្រកូលរាជ-សម្បត្តិជាដើម ក៏ព្រោះកម្មបុណ្យ សេចក្ដីល្អដែលទ្រង់បានកសាងសន្សំទុកជាលំដាប់ជាតិៗមក ។

ព្រះលោកនាថប្រកបដោយព្រះមហាករុណាទិគុណ ទោះបីព្រះអង្គបានសេចក្ដីសុខស្រួលដូចម្ដេច ក៏មិនទ្រង់ឲ្យលក់ជក់ងប់ជាប់ព្រះទ័យឲ្យទាល់តែលង់ទាំងគំនិតដល់ក្រេបទឹកមិនឃើញ នូវការសុខទុក្ខរបស់ពពួកសត្វដែលលិចលង់ក្នុងលោកសន្និវាសនេះទេ, ព្រះអង្គមិនព្រមទទួលសោយសេចក្ដីសុខថ្កុំថ្កើងជាផលសំណាងដែលបានមកតាំងនៅស៊ប់ក្នុងកណ្ដាប់ព្រះហស្ដរបស់ព្រះអង្គតែមួយព្រះអង្គប៉ុណ្ណោះទេ ទ្រង់ស៊ូលះបង់ប្រយោជន៍ទាំងនោះចោលស្រឡះមិនទីកនា ខំប្រឹងបំពេញព្យាយាមទាល់តែបានសម្រេចប្រាជ្ញាពោធិញ្ញាណលើរតនបល្ល័ង្ក ព្រះអង្គបានទៅជាសត្ថនាយកៈអ្នកដឹកនាំស្រោចស្រង់សត្វទៅក្នុងលោក ឲ្យផុតពីសេចក្ដីទុក្ខលំបាកមានកើត, ចាស់, ឈឺ, ស្លាប់ជាដើម (ដូចជាសំពៅធំ) ។

ចាប់ដើមតាំងពីត្រឹមឆ្នាំដែលទ្រង់បានត្រាស់ដឹងមក ព្រះអរហំសម្មាសម្ពុទ្ធ ស្ដេចយាងទៅប្រកាសសាសនាប្រទានឲ្យពាក្យប្រៀនប្រដៅណែនាំពពួកសត្វមានមនុស្សនិងទេវតាជាដើម. ខំប្រឹងព្យាយាមសំដែងធម៌បកស្រាយពន្យល់ប្រាប់គុណ, ទោស, ខុស, ត្រូវ ឲ្យសត្វយល់ឃើញ

ពិតៗ ឥតព្រួញពនឹងសេចក្ដីនឿយព្រួយ ព្រះកាយពលក្នុងការប្រកាសប្រាប់ប្រយោជន៍របស់សត្វទាំងនោះឡើយ ។

ព្រះអង្គទ្រង់ប្រឹងបំពេញពុទ្ធកិច្ចគ្រប់គ្រាន់មិនមានចន្លោះសមស័ក្តិព្រះអង្គជា សត្ថនាយកៈ អ្នកដឹកនាំស្រោចស្រង់ជាទីពឹងពាក់ពំនាក់អាស្រ័យនៃសត្វក្នុងត្រៃលោកមែនៗ ទាំងមានព្រះឥរិយាបថស្រគត់ស្រគមសមរម្យ មានព្រះអធ្យាស្រ័យដ៏ទន់ក្លន់ស្មោះស្មើ ស្មុតត្រង់ទៅរកសត្វទូទៅ, គួរឲ្យមនុស្សទេវតានឹងសត្វគ្រប់ថ្នាក់ មានសេចក្ដីសង្ឃឹមកក់ក្ដៅចូលទៅជ្រកកោនក្រោមម្លប់ពោធិសម្ភារ បានសម្រេចសន្តិសុខតាមប្រាថ្នា; ព្រះអង្គមានទំនងគួរឲ្យសត្វក្នុងសកលលោកគោរពក្រាបសំពះយកតម្រាប់តាម ដោយសេចក្ដីពេញចិត្តមិនបាច់បង្ខំ ។

ព្រះពុទ្ធគុណដែលរៀបរាប់មកខាងលើនេះ បើពោលបំព្រួញឲ្យខ្លីឆាយចំណាំជាងនោះមកទៀត ថា ព្រះអរហំសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ទ្រង់មានព្រះទ័យស្អាត មិនប្រឡាក់ដោយបាបសេចក្ដីអាក្រក់ណាមួយ ដូច្នេះហៅថា វិសុទ្ធិគុណ ។ ទ្រង់ខំប្រឹងបំពេញប្រយោជន៍ឲ្យសត្វបានទទួលសេចក្ដីសុខតាមគតិលោកគតិធម៌ពលគា សមគួរដល់កំពូលសំណាងសត្វ មិនលាក់បិទប្រយោជន៍ទុកសម្រាប់សោយសេចក្ដីសុខស្រួលតែមួយព្រះអង្គឡើយ ដូច្នេះហៅថា ករុណាគុណ ។ ទ្រង់មាន

បាយដ៏ប្រពៃក្នុងការទូន្មានសត្វ ធ្វើសេចក្ដីជ្រៅឲ្យរាក់ កំបាំងឲ្យស្រាយ យល់ ស្រាយគិតជាដើម ដូច្នេះហៅថា បញ្ញាគុណ ។

ដោយហេតុនេះទើបប្រាកដថា ព្រះពុទ្ធគ្រប់ព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក ជាហេតុនាំឲ្យបានសេចក្ដីសុខ (ដល់ពួកសត្វក្នុងត្រៃភព) ។ សេចក្ដីដែលសំដែងមកនេះជាគុណដែលមានក្នុងព្រះអង្គ ។

ស្វាក្ខាតោ ភគវតា ធម្មោ ធម៌ដែលព្រះសម្ពុទ្ធសំដែងដោយប្រពៃ មានគុណអាចស្រោចស្រង់សត្វលោកដែលពេញចិត្តកាន់តាមឲ្យផុតអំពីទុក្ខទោស បានសេចក្ដីសុខស្រួលឃើញជាក់ច្បាស់ចំពោះមុខភ្លាមៗ តាមថ្នាក់តាមជាន់ឥតបង្អង់ចាំកាលវេលា ។ ធម្មោ សុចិណ្ណោ សុខមាវហាតិ ធម៌ដែលសត្វបានរក្សាទុកត្រឹមត្រូវ នឹងផ្ដល់សេចក្ដីសុខមកឲ្យវិញពុំខាន ។

អធិប្បាយថា: អំពើល្អហៅថាធម៌, អ្នកប្រព្រឹត្តត្រឹមត្រូវតាមធម៌ ឈ្មោះថាបានរក្សាធម៌ទុកដោយប្រពៃ នឹងត្រូវបានផលជាសុខ; អ្នកមិនកាន់តាមធម៌នឹងត្រូវបានផលជាទុក្ខ ។ រួមព្រះធម៌ទាំង ៨៤០០០ ធម្មក្ខន្ធ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងហៅថាពុទ្ធសាសនា ។

សាធុជន ដែលពេញចិត្តគាប់អធ្យាស្រ័យក៏ចង់បានប្រយោជន៍សេចក្ដីសុខសេចក្ដីចំរើនត្រឹមតែក្នុងលោកនេះក៏គួរតែបង្អោនចិត្ត ចូលមក

កាន់ព្រះពុទ្ធសាសនាកុំខាន ព្រោះព្រះពុទ្ធសាសនានេះ អ្នកប្រាជ្ញជាន់ខ្ពស់ក្នុងលោក បានពិនិត្យឃើញពិតថា ជាសាសនាមានអានុភាពអាចធ្វើលោកឲ្យស្ងប់, ទាំងញ៉ាំងមនុស្សសត្វដែលទន់ទាប់ថោកថយឲ្យខ្ពង់ខ្ពស់ថ្លៃថ្នូរ, បើថ្លៃថ្នូរស្រាប់ ឲ្យរឹងរឹតតែវិសេសក្រៃលែងឡើងទៀត ៗ សេចក្ដីដែលពណ៌នាមកនេះ ត្រង់តាមគោលដើមនៃពុទ្ធបំណងពិត, ព្រោះព្រះអង្គដែលខំប្រឹងព្យាយាមសំដែងច្បាប់ប្រាប់ពន្យល់មិនខ្លាចនឿយហត់ទាំងម៉្លេះ ដោយទ្រង់មានព្រះទ័យករុណាចង់ដោះស្រាយពួកសត្វដែលជាប់ចំណងនៃសេចក្ដីទុក្ខលំបាកមានជាតិ, ជរា, ព្យាធិ, មរណៈជាដើម ឲ្យរួចចាកទុក្ខបានសេចក្ដីសុខស្កប់ស្កល់ប៉ុណ្ណោះ ៗ

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថា ពួកមនុស្សសត្វកើតមកពេញទាំងសកលលោក សុទ្ធសឹងតែប្រាថ្នាសេចក្ដីខ្ពង់ខ្ពស់ថ្លៃថ្លាគ្រប់ ៗ រូប, ដែលបែរជាបានសេចក្ដីអាប់ឱនទន់ទាប មិនសមដូចបំណងស្មើគ្នាទៅវិញនោះ បណ្ដាលមកពីហេតុច្រើនយ៉ាងណាស់, ខ្លះកើតឡើងដោយសេចក្ដីទន់ទាបក្រីក្រល្ងង់ខ្លៅស្រាប់មកអំពីកំណើតក៏មាន ព្រោះផលបុព្វេតិប, ខ្លះកើតមកបានជួបប្រទះនឹងសេចក្ដីថ្កុំថ្កើងសម្បូណ៌សម្បត្តិគ្រប់គ្រាន់ស្រាប់ពីកំណើត តែធ្វេសភ្លេចគិតបណ្ដោយចិត្តឲ្យទៅប្រព្រឹត្តអាក្រក់ទាស់ទំនង ពាន់ទៅលើអំពើមិនមែនជាធម៌ បានសេចក្ដីថ្លស់

ដោយធ្លាក់ខ្លួនជាអ្នកទន់ទាបអាប់ឱនខូចទៅវិញក៏មាន, ខ្លះទប់ខ្លួនឲ្យនៅត្រឹមតែស្មើៗ មិនទាបមិនខ្ពស់ក៏មាន, តាមសមគួរដល់អំពើដែលសត្វបានធ្វើរៀងៗខ្លួន ; ដូចពុទ្ធភាសិតថា សត្តេ កម្មំ វិភជ្ជតិ កម្មគឺអំពើដែលសត្វធ្វើទុកមកអំពីជាតិមុន ឬជាតិនេះជាមេចំណែកចែកឲ្យសត្វបានសុខបានទុក្ខផ្សេងៗគ្នា មិនមែនអ្វីផ្សេងក្រៅពីអំពើរបស់ខ្លួននោះចែកឲ្យឡើយ ។

ឯអំពើអាក្រក់ នាំមនុស្សឲ្យវិនាសបានសេចក្ដីទុក្ខលំបាកទាំងលោកនេះនឹងលោកខាងមុខនោះ គឺ:

អបាយមុខ (ហេតុដែលនាំឲ្យវិនាសសេចក្ដីចំរើន) ៤ យ៉ាងគឺ:

១— ឥត្ថីធុត្ត: អ្នកលោភចិត្តជក់នឹងមាតុគ្រាម មិនមានចិត្តសន្តោសត្រឹមតែភរិយា - ស្វាមីរបស់ផងខ្លួន

២— សុរាធុត្ត: អ្នកសេពគ្រឿងស្រវឹង

៣— អក្ខធុត្ត: អ្នកលេងល្បែងភ្នាល់

៤— បាបមិត្ត: អ្នកគប់រកមនុស្សអន្ធពាល អាក្រក់ជាមិត្រ ។

ហេតុទាំង ៤ នេះសុទ្ធសឹងតែជាអំពើអាក្រក់ អាចនាំឲ្យប្រទេសជាតិមាតុភូមិ គោត្តសម្ព័ន្ធនឹងបរិយាស្រក់ស្រុតចុះថោកទាបនាំឲ្យវិនាសខូចស់ដោយខូចបង់ប្រយោជន៍សេចក្ដីសុខចំរើន របស់មនុស្សក្នុងសកលលោក

ជាគំនែ្ហងក្លាមៗ មិនបាច់ពោលថ្វីទៅលោកខាងមុខនោះឡើយ ។ មែន
ពិត, អំពើទាំងនេះ បើសត្វខំប្រឹងប្រព្រឹត្តជាប់មិនលែង លោកពោលថា
ទុកដូចជាគប់ភ្លើងយ៉ាងធំ មកដុតកោលកំទ្បាចបំផ្លាញគោរគសម្បត្តិ
បំណេះវិជ្ជា, បរិយា, មារយាទ, ជាតិកំណើត, និងសន្តិសុខ ដ៏រុងរឿង
របស់ខ្លួនឲ្យខ្ទាចខ្ទីនខ្ទប លែងលូតលាស់ដុះបំរើនឡើងទៀត រូបបេះ
តែរេចរិលទៅជានិច្ច ឈ្មោះថាមនុស្សជ្រួញទុក្ខ ។

បុគ្គលគួរកុំប្រព្រឹត្តអំពើទាំងនេះឲ្យសោះ កាលបើយើងវៀរចាក
អំពើទាំងនេះរួចស្រឡះហើយ ឈ្មោះថាបានប្រព្រឹត្តធម៌ រក្សាធម៌ទុក
ដោយប្រពៃ នឹងបានផលជាសុខច្រើនប្រការ; បើពោលដោយ
សង្ខេបវិញ គឺ:

១ — សុខព្រោះមានចិត្តស្រះស្រួលស្មោះស្មើទៅរកស្វាមីភរិយា
ដោយមិនជាប់ចិត្តនឹងបុរស-ស្ត្រីឯទៀត;

២ — សុខព្រោះមានសំដីកបសាជាប្រក្រតី មិននិយាយឡេះឡោះ
កកែកករករឿងឈ្លោះ មិនខូចបង់ប្រាក់កាស ដោយហេតុមិនសេពសុរា;

៣ — សុខព្រោះបានធ្វើការងារចំរើន រៀនវិជ្ជាបេះចាំមិនភ័យនឹង
អ្នកពជការចាប់ចង ឃុំឃាំងលក់ព្រៃ ដោយហេតុមិនលេងល្បែងភ្នាល់;

៤ — សុខព្រោះចិត្តស្លូតត្រង់ មិនបេះធ្វើអំពើអាក្រក់ ដោយហេតុ
មិនសេពគប់រកជនពាល ។

ឯការគប់រកជនអន្ធពាល នាំឲ្យបេះចំណេះអាក្រក់ ព្រោះមនុស្សពាលមិនដែលមានសមត្ថភាព ខាងឯនាំឲ្យប្រព្រឹត្តល្អទេ មិនស្គាល់ហេតុនាំឲ្យបានសុខ ស្តាប់ពាក្យត្រូវមិនសូវបាន, បើអ្នកដែលទៅសេពគប់មិនចេះលេងស្រី នាំឲ្យចេះលេងស្រី, មិនចេះសេពសុរា នាំឲ្យចេះសេពសុរា, មិនចេះលេងល្បែងភ្នាល់ នាំឲ្យចេះល្បែងភ្នាល់, រហូតដល់ទៅនាំឲ្យចេះដើរលេងយប់, ពោកប្រាស់បំបាត់ប្រវ័ញ្ចគេ ធ្លាក់ដល់ចេះលួចប្លន់កាប់សម្លាប់គេក៏សឹងមាន; ត្រូវនឹងពុទ្ធភាសិតថា អសេវនា ច ពាលានំ ការមិនគប់រកពួកជនពាល ចាត់ជាមង្គលដ៏ប្រសើរ ។

អ្នកដែលវៀរចាកអំពើអាក្រក់ ដូចបានពោលមកហើយនេះ ទុកដូចជាអ្នកបានបណ្តុះប្រយោជន៍ដ៏ធំទូលាយចំពោះខ្លួនផង ទុកសម្រាប់ប្រទេសជាតិមាតុភូមិ ឲ្យដើរលឿនទៅកាន់វឌ្ឍនធម៌ខាងអនាគតផង ។ សេចក្តីសុខទុក្ខទាំងនេះកើតមកអំពីកម្មផ្ទាល់ខ្លួនពិត ៗ ការលះបង់អបាយមុខមានប្រយោជន៍ដ៏ធំទូលាយក្រៃពេក ។ ដែលសំដែងមកនេះជាសេចក្តីសង្ខេប ។

មិនត្រឹមតែប៉ុណ្ណោះដែលហៅថាសាសនាបរិសុទ្ធនោះ គឺជាសាសនាអាចញ៉ាំងលោកឲ្យលឿនទៅកាន់សេចក្តីចំរើន ទប់សត្វមិនឲ្យធ្លាក់ទៅកាន់ទីវេទនាមាននរកជាដើម ឲ្យលោកបានសេចក្តីសុខស្ងប់ ទាំង

ធ្វើឲ្យអ្នកជឿស្តាប់កាន់តាម បានប្រទះប្រយោជន៍សេចក្តីចំរើនដោយ ភោគសម្ប័ទបញ្ញាសម្ប័ទ កេរ្តិ៍ឈ្មោះយសសក្តិតាមសមគួរ មិនមែនសំដែងប្រាប់ឲ្យមនុស្សសត្វ ដេកទ្រមន់ចាំសំណាងពីព្រេងនាយតែម្យ៉ាងទេ ដូចពុទ្ធភាសិតថា សុស្សូសំ លភតេ បញ្ញំ អ្នកមានប្រាជ្ញាចេះចំណេះវិជ្ជាគ្រប់យ៉ាងបានមកពីប្រឹងរៀនស្តាប់ទន្ទេញ មិនធ្វេសប្រហែសក្នុងការរៀនសូត្រ ឧដ្ឋាតា វិន្ទតេ ធនំ អ្នកមានទ្រព្យគ្រប់គ្រាន់មកពីរវៀសរវៃប្រឹងរកប្រឹងធ្វើមិនខ្ជិល ។ សេចក្តីដែលសំដែងមកប៉ុណ្ណោះតាមលំអានព្រះពុទ្ធសាសនា ជាសាសនាប្រាប់ផ្លូវប្រតិបត្តិយ៉ាងកណ្តាល មិនឲ្យសត្វកាន់ឆាកធ្លាក់ទៅលើផ្លូវប្រតិបត្តិខ្វេងដែលហៅថា អត្ត បដិបទា សេចក្តីប្រតិបត្តិដ៏លាមក ឬអមងាងនោះឡើយ មានទំនងឲ្យពួកពុទ្ធបរិសទ្យ នាំគ្នាកាន់តាមសេចក្តីពេញចិត្តឥតបង្ខិតបង្ខំ ។

ព្រោះហេតុនោះ ទើបអធិប្បាយថាជាសាសនា ស្អាងលោកឲ្យរុងរឿង ទប់សត្វមិនឲ្យធ្លាក់ទៅកាន់ទីទាប ។

អាត្មាភាពសំដែងមកអំពីដើមកំណើតនៃសេចក្តីសុខ សូមសន្មតថាចប់ដោយសង្ខេបតែប៉ុណ្ណោះ ឯវំ ។

# វម្មិកបញ្ហា

## ព្រះមហា ប័ន្ទ-ហុង

## វត្តបល័ង្ក ឃុំពង្រ ស្រុករលាប្អៀរ ខេត្រកំពង់ឆ្នាំង

### រៀបរៀង

---

ពាក្យថា "វម្មិក:" នេះ ប្រែថា "ដំបូក" គឺសូត្រសំដែងអំពីរូបកាយ ដោយយកដំបូកមកប្រៀបធៀប ។ ព្រះសូត្រនេះ ព្រះបរមសាស្ដាទ្រង់សំដែងក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ចំពោះកុមារកស្សបព្រាហ្មណ៍ ដូច្នេះថា ៖

១ – អ្វីហ្ន៎ហៅថាដំបូក?

២ – អ្វីហុយផ្សែងក្នុងពេលយប់?

៣ – អ្វីឆេះក្នុងពេលថ្ងៃ?

៤ – អ្នកណាជាព្រាហ្មណ៍?

៥ – អ្នកណាជាសុមេធ?

៦ – អ្វីជាសស្ត្រា?

៧ – អ្វីជាការជីក?

៨ – អ្វីជាសន្ទះទ្វារកង់?

៩ – អ្វីជាសត្វហ៊ឹង?

១០ - អ្វីជាផ្លូវបែកជាពីរ ?

១១ - អ្វីជាសំពត់ជម្រងក្បួន ?

១២ - អ្វីជាអណ្តើក ?

១៣ - អ្វីជាកាំបិតនឹងជ្រញ់ ?

១៤ - អ្វីជាដុំសាច់ ?

១៥ - អ្វីជានាគ ?

ប្រស្នាទាំង ១៥ នេះនឹងសូមលើកយកមួយម្តងៗ មកអធិប្បាយតទៅ ។

## អ្វីហៅថា ដំបូក ?

កាយដែលប្រកបដោយមហាភូតរូប ៤ គឺ ដី, ទឹក, ភ្លើង, ខ្យល់ បានឈ្មោះថា ដំបូក ។

អធិប្បាយ: សភាវៈធម៌ដែលប្រកបដោយ "សង្ខតធម៌" គឺធម៌មានបច្ច័យប្រជុំតាក់តែងឲ្យកើតបានទៅជារូប មានសណ្ឋានទ្រង់ទ្រាយ មានពណ៌សម្បុរដោយអំណាចធាតុ ៤ ទ្រទ្រង់ គឺ:

១ - ធាតុដី

២ - ធាតុទឹក

៣ - ធាតុភ្លើង

៤ - ធាតុខ្យល់ ។

ធាតុណាដែលមានលក្ខណៈរឹងប៉ឹងមាំមួនជាងគេ ធាតុនោះឈ្មោះថាបឋវីធាតុ ។ នោះដែលជាខាងក្នុង ១៩ គឺ: សក់, រោម, ក្រចក, ធ្មេញ, ស្បែក, សាច់, សរសៃ, ឆ្អឹង, ខួរក្នុងឆ្អឹង, តម្រងបស្សាវៈ(១), បេះដូង, ថ្លើម, ភាវ, ក្រពះ, សួត, ពោះវៀនធំ, ពោះវៀនតូច, អាហារថ្មី, អាហារចាស់ ។

ធាតុណាមានលក្ខណៈហូរជ្រួតជ្រាប ធាតុនោះឈ្មោះថា អាបោធាតុ ។ នោះដែលជាខាងក្នុង ១២ គឺ: ប្រមាត់, ស្លេស្ម, ខ្ទុះ, ឈាម, ញើស, ខ្លាញ់ខាប់, ទឹកភ្នែក, ខ្លាញ់រាវ, ទឹកមាត់, ទឹកសំបោរ, ទឹករំអិល, ទឹកមូត្រ (២) ។

ធាតុណាដែលមានលក្ខណៈក្តៅ ធាតុនោះឈ្មោះថា តេជោធាតុ ។ នោះដែលជាខាងក្នុង ៤ គឺ:

១ – ភ្លើងដែលញុំាងកាយឲ្យក្តៅ
២ – ភ្លើងដែលញុំាងកាយឲ្យទ្រុឌទ្រោម
៣ – ភ្លើងដែលញុំាងកាយឲ្យក្រហល់ក្រហាយ
៤ – ភ្លើងដែលដុតអាហារឲ្យរលួយ ។

---

១ តម្រងបស្សាវៈនេះ បាលីថា វក្កំ ដែលធ្លាប់ប្រែមកថា ទាច, តែបើតាមសេចក្តីពិតគឺតម្រងបស្សាវៈទេ, ទាចនុះជាឈ្មោះរបស់ពោតទេតើ ។ ២ ក្នុងសូត្រដទៃ ៗ អាការៈនោះមានត្រឹមតែ ៣១ ប៉ុណ្ណោះ, តែអដ្ឋកថាឃើញមានបន្ថែម មត្ថកេ មត្ថលុង្គំ (ខួរក្នុងក្បាល) ដូច្នេះទើបគ្រប់ជា អាការៈ ៣២ ។

ធាតុណាដែលមានលក្ខណៈបក់ទៅមក ។ ធាតុនោះឈ្មោះថា វាយោធាតុ ។ នោះដែលជាខាងក្នុង ៦ គឺ:

១ - ខ្យល់បក់ឡើងលើ

២ - ខ្យល់បក់ចុះក្រោម

៣ - ខ្យល់បក់ក្នុងពោះ

៤ - ខ្យល់បក់ក្នុងពោះវៀន

៥ - ខ្យល់បក់តាមពង្សកាយ

៦ - ខ្យល់ដកដង្ហើមចេញចូល ។

បណ្ឌិតគប្បីកំណត់ពិចារណាកាយនេះឲ្យឃើញថា គ្រាន់តែជាធាតុ ៤ ប្រជុំគ្នាប៉ុណ្ណោះ មិនមែនជាយើងជាគេឡើយ យ៉ាងនេះហៅថា ធាតុកម្មដ្ឋាន ។

មួយវិញទៀត គប្បីពិចារណាថា កាយនេះជារូបធម៌តែងប្រែប្រួលគ្រប់ឥរិយាបថទាំង៤ គឺ ដេក, ដើរ, ឈរ, អង្គុយ, ក៏ក្នុងសាសនានេះ កាលបើដេកក្តី, ដើរក្តី, ឈរក្តី, អង្គុយក្តី, ក៏គប្បីឲ្យដឹងច្បាស់ថា អាត្មាអញ ដេក, ដើរ, ឈរ, អង្គុយ, យ៉ាងនេះហៅថា ការពិចារណាក្នុងឥរិយាបថ ។

មួយពិចារណាថា កាយនេះជាសាកអសុភ ៩ យ៉ាង គឺ:

១ - សាកអសុភដែលគេយកទៅបោលក្នុងព្រៃស្មសានទៅថ្មី ។

ចំនួន ១ ថ្ងៃ ឬ ២ ថ្ងៃដ៏មានសម្បុរខៀវហើមឡើង ប្រកបដោយខ្ទុះហូរ
ចេញមកខាងក្រៅ ៗ

២ – សាកអសុភដែលមានសត្វរុយ ក្អែក ត្មាត ហោមចឹកស៊ីជាដើម

៣ – សាកអសុភនៅតែពងឆ្អឹង មានសរសៃទងសាច់ឈាម

៤ – សាកអសុភ មានតែសរសៃទងឆ្អឹងមានឈាមប្រឡាក់

៥ – សាកអសុភ មានត្រឹមតែសរសៃទងឆ្អឹងឥតឈាមប្រឡាក់

៦ – សាកអសុភមានតែឆ្អឹងជាប់កាត់កាយខ្ចាត់ខ្ចាយពីគ្នា

៧ – សាកអសុភពងឆ្អឹងមានសម្បុរស

៨ – សាកអសុភមានតែឆ្អឹងសល់នៅគរ ចំនួន ១ ឆ្នាំ

៩ – សាកអសុភនៅតែកំទេចឆ្អឹងល្អិត ៗ ៗ

បណ្ឌិតគប្បីពិចារណានូវអសុភកម្មដ្ឋានទាំង ៩ យ៉ាងនេះ ដោយការប្រៀបធៀបឲ្យឃើញច្បាស់នូវកាយរបស់យើងថា ជារបស់ពុកផុយរលួយម៉ត់គ្មានខ្លឹមសារ ព្រោះមានសភាវៈមិនទៀងទាត់ឋិតថេរចិរកាល, ហេតុនោះបានជាព្រះអង្គសំដែងថា "ត្រូវតែលះបង់នូវនិច្ចសញ្ញា (១) សុខសញ្ញា (២) អត្តសញ្ញា (៣) ចេញ, ហើយគប្បីចំរើននូវអនិច្ចសញ្ញា ទុក្ខសញ្ញា អនត្តសញ្ញា" ដោយសេចក្តីសំគាល់ថា "កាយជារបស់មិនទៀង ប្រកបដោយទុក្ខ (៤) មិនមែនជារបស់យើងទេតែងឈឺចាប់

---

១-២-៣- សេចក្តីសំគាល់ថាទៀង, ថាសុខ, ថាខ្លួន ។ ៤ បានដល់ទុក្ខទាំង ១២ កងមានជាតិទុក្ខជាដើម មានយម្បិទុំ ៩ លភតិ គម្បិទុក្ខ ជាអវសាន ។

ទ្រង់ត្រាស់ទុក មានសេចក្តីស្លាប់ជាទីបំផុត សមនឹងសុភាសិតថា

ឯវំ ជរា ច មច្ចុ ច អធិវត្តន្តិ បាណិនោ
ខត្តិយេ ព្រាហ្មណេ វេស្សេ សុទ្ទេ ចណ្ឌាលបុក្កសេ

ប្រែថា សេចក្តីចាស់ជរា (ឈឺចាប់) នឹងសេចក្តីស្លាប់ តែងគ្របសង្កត់សង្កិន (ញាំញី) នូវពពួកសត្វទាំងឡាយ (ក្នុងលោក) (ឥតមានរើសមុខឬយល់មុខ) ថា ក្សត្រ, ព្រាហ្មណ៍, អ្នកជំនួញ, ពួកគូលី, ចណ្ឌាល, អ្នកចាក់សំរាមយ៉ាងនេះ (ទេ) ។

ម្យ៉ាងទៀត បើត្រូវនឹងស្លាប់ហើយ ទោះបីរត់ពួនសម្ងំត្រាំត្រែងក្នុងក្រំថ្ម ក៏នៅតែមិនរួចអំពីសេចក្តីស្លាប់បានឡើយ ។ ដូចពុទ្ធភាសិតដែលព្រះអង្គទ្រង់សំដែងប្រារព្ធនឹងសក្កៈឈ្មោះសុប្បពុទ្ធថា

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតេ សោ ជគតិប្បទេសោ
យត្រដ្ឋិតំ នប្បសហេយ្យ មច្ចុ

ប្រែថា (បើ) បុគ្គលចូលទៅក្នុងពពកក្តី, ចូលទៅក្នុងមហាសមុទ្រមានជម្រៅ ៨៤ ០០០ យោជន៍ក្តី, ចូលទៅកាន់ចន្លោះប្រញកនៃភ្នំក្តី ក៏មិនគប្បីរួចអំពីសេចក្តីស្លាប់បានឡើយ ព្រោះរកប្រទេសលើផែនដីដែលសេចក្តីស្លាប់មិនគប្បីបៀតបៀន នូវបុគ្គលបាននោះគ្មានទេ ។

## អ្វីហុយផ្សែងក្នុងពេលយប់?

បុគ្គលបានប្រកបកិច្ចការងារក្នុងវេលាថ្ងៃ ហើយត្រិះរិះក្នុងវេលាយប់ បានឈ្មោះថា បង្ហុយផ្សែងក្នុងរាត្រី ។ ពាក្យថា ហុយផ្សែងក្នុងរាត្រីនេះ ជាឈ្មោះរបស់បំណង ដែលបានចងទុកជាមូលហេតុ ព្រោះថា ការងារដែលត្រូវធ្វើដោយកាយក្តី វាចាក្តី គាស្រ័យនឹងសេចក្តីត្រិះរិះគិតគូរទុកជាមុន ត្រូវនឹងបុរាណភាសិតថា "មុននឹងគូរត្រូវគិត មុននឹងប្រព្រឹត្តត្រូវពិចារណា" ។ កិច្ចការទាំងពួង ដែលធ្វើទៅល្មៀន មិនប៉ះទង្គិចនឹងរបស់គុណាមួយ ក៏ព្រោះតែសេចក្តីត្រិះរិះជាដើម ។ គំនិតចិត្តហ្នឹងឯងដែលជាម្ចាស់កាយវាចា តែងចាត់ចែងការគ្រប់ជំពូក ។

## អ្វីឆេះក្នុងពេលថ្ងៃ?

បុគ្គលត្រិះរិះក្នុងពេលយប់ ហើយប្រកបការងារក្នុងវេលាថ្ងៃ បានឈ្មោះថាឆេះក្នុងពេលថ្ងៃ ។

បុគ្គលត្រិះរិះជ្រើសការងារដែលត្រឹមត្រូវតាមផ្លូវពុទ្ធសាសនា រមែងទទួលផលប្រយោជន៍ ៣ យ៉ាង គឺ:

១ – ប្រយោជន៍ក្នុងបច្ចុប្បន្ន
២ – ប្រយោជន៍ក្នុងបរលោក
៣ – ប្រយោជន៍ដ៏ឧត្តមគឺព្រះនិព្វាន ។

## ប្រយោជន៍ក្នុងបច្ចុប្បន្ន មាន ៤ យ៉ាង

១ — ឧដ្ឋានសម្បទា បរិបូណ៌ដោយការលះបង់នូវសេចក្ដីខ្ជិលច្រអូស ហើយក្រោកឡើងស្រក់ស្រទេញចាប់ការងារឥតធុញទ្រាន់ គឺការស្វែងរកនូវភោគសម្បទ ដែលមិនប្រកបដោយទោស[1] មានកសិកម្ម និងពាណិជ្ជកម្ម ទៅតាមយថាពលំរបស់ខ្លួន ដើម្បីឲ្យកើតសេចក្ដីសុខចំរើន មិនកំណត់កាលវេលាឬដាក់ធុរៈក្នុងកិច្ចការងារដែលត្រូវធ្វើ ។

— ២ អារក្ខសម្បទា បរិបូណ៌ដោយការរក្សាថែទាំរៀបចំទុកដាក់ទ្រព្យសម្បត្តិ ដែលខ្លួនរកបានមកហើយកុំឲ្យវិនាសខ្ចាត់ខ្ចាយអន្តរាយ ព្រោះល្បែងផ្សេងៗ មានល្បែងស្រីស្រាកញ្ឆាអាភៀន និងល្បែងភ្នាល់ជាដើម ល្បែងទាំងនេះជាផ្លូវនៃសេចក្ដីខ្ចាត់ក្ខាត់វិនាសបង់ ប្រាសចាកសុខភាព អនាម័យ ។

៣ — កល្យាណមិត្តតា ភាវៈជាអ្នកគប់រកកល្យាណមិត្រ ដែលមានកល្យាណកម្មប្រចាំក្នុងខន្ធសន្ដាន ទើបបានសេចក្ដីចំរើនដោយលាភនិងយសសក្ដិមានឋានៈដ៏ខ្ពង់ខ្ពស់ ព្រោះការសេពគប់នឹងកល្យាណមិត្រនេះ អាចធ្វើមនុស្សឲ្យក្លាយពីហីនភាពទៅកាន់ឧត្ដមភាព, ឲ្យឡើងពីមូឡ្ហភាពទៅកាន់បណ្ឌិតភាព, ឲ្យឡើងពីទុក្ខភាពទៅកាន់សុខភាព,

---

១ វៀរចាកបញ្ឆោត ។

ឲ្យឡើងពីអន្ធបុថុជ្ជនទៅកាន់កល្យាណបុថុជ្ជន, ឲ្យឡើងពីកល្យាណ-បុថុជ្ជនទៅកាន់អរិយជន, មានគុណសម្បត្តិសមត្ថភាពដ៏ថ្លៃថ្លាស្ថាពរ បរិបូណ៌ដោយមហិទ្ធិរិទ្ធិជាតិយេស្យភាពតទៅ ។ —

៤ — សមជីវិតា ប្រកបការអាជីពចិញ្ចឹមជីវិតល្មមសមគួរដល់កម្លាំងទ្រព្យធនធានដែលខ្លួនមាន គឺថាកុំគប្បីចាយវាយភោគសម្បទឲ្យហួសហេតុខុសទំនង ។

## អ្នកមានក្លាយទៅជាអ្នកក្រដោយហេតុ ៤ យ៉ាង [1]

១ — មិនរំប្រឹងរករបស់ដែលបាត់

២ — មិនជួសជុលរបស់ចាស់

៣ ស៊ីផឹកចាយវាយទ្រព្យសម្បត្តិឥតកំណត់

៤ — លើកមនុស្សទ្រុស្តសីលឲ្យជាធំ ។

ឯប្រយោជន៍ក្នុងបច្ចុប្បន្នទាំង ៤ យ៉ាងដែលបុរសស្ត្រីគេបានមកប្រកបដោយធម៌ មិនឈ្មោះថា "តណ្ហា" ទេ, បានជាថាដូច្នោះព្រោះពាក្យថា "តណ្ហា" នេះសំដៅយកមនោចេតនាដែលអោបស្ងួតទ្រព្យសម្បត្តិមិនចែកចាយចំណាយធ្វើបុណ្យកុសល ហាមមិនជីកអណ្តូង, មិនលើកស្រះ, មិនដាំដើមឈើ, មិនសង់ស្ពាន, មិនសាងផ្លូវថ្នល់ជាដើម ៗ សេចក្តីស្ងួតស្ងាញបែបនេះ ទើបឈ្មោះថា "តណ្ហា" ។

១ មាននៅក្នុងគម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត ។

បុរសស្ត្រីណាដែលមានសេចក្តីកំណាញ់កាញ់សម្បត្តិទុក ដូចរៀបរាប់មកនេះ ឈ្មោះថាជាបុគ្គលមានសេចក្តីសុខតិចដោយហេតុតែមិនបែងចែកសេចក្តីសុខឲ្យដល់អ្នកដទៃព្រោះតែសេចក្តីកំណាញ់ ដូច្នេះ សាធុជនគួរប្រព្រឹត្តធ្វើតាមពុទ្ធភាសិតក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយ ត្រង់បកិណ្ណកវគ្គ ថា:

មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ

ប្រែថា បើបុគ្គលឃើញនូវសេចក្តីសុខដ៏ធំទូលាយហើយ គប្បីលះបង់នូវសេចក្តីសុខមានប្រមាណតិចចេញ អ្នកប្រាជ្ញកាលឃើញនូវសេចក្តីសុខដ៏ធំទូលាយ តែងលះបង់សេចក្តីសុខតូចតាចចោល ៗ

ការដែលលះបង់សេចក្តីសុខដែលមានប្រមាណតិច ដើម្បីប្តូរយកវិបុលសុខ គួរតែអនុវត្តន៍ធ្វើនូវប្រយោជន៍ក្នុងលោកខាងមុខតទៅទៀត ។

(មានត)

# រឿងព្រេងជួននិទាន

## ឃុនបណ្ឌិតរក្ស ប៊ូ-ប៊ូ រៀបរៀង

*តាមសេចក្ដីដំណាលរបស់លោកហង់-គីមសេង*

---

## ១.— រឿងអ្នកជួយសង្គ្រោះគេ

មានតាចាស់ម្នាក់ជាជាតិយីពុន សង់ផ្ទះនៅក្បែរមាត់សមុទ្រ គាត់ជាអ្នកដឹងពេលទឹកសមុទ្រជោរ ។ ថ្ងៃមួយជិតនឹងដល់ពេលទឹកសមុទ្រជោរ មានមនុស្សជាច្រើននាក់នាំគ្នាចុះទៅរកចាប់ក្ដាមនៅមាត់សមុទ្រ បានទៅជួបនឹងតាចាស់នោះៗ ឃាត់ថា "អ្នករាល់គ្នាកុំចុះទៅ ដ្បិតទឹកសមុទ្រជិតជោរជន់ហើយ បើបេះតែចចេសទៅ មុខជាលង់ទឹកស្លាប់ទាំងអស់គ្នាមិនខាន" ។ អ្នកចាប់ក្ដាមទាំងនោះមិនព្រមស្ដាប់ បេះតែនាំគ្នាចុះទៅចាប់ក្ដាម ។ ពេលនោះតាចាស់យកភ្លើងដុតផ្ទះរបស់ខ្លួនឲ្យឆេះហុយផ្សែងទ្រលោមហើយស្រែកហៅឲ្យគេជួយលត់ភ្លើង ។ អ្នកចាប់ក្ដាមទាំងអស់បានឮដូច្នោះ ក៏ក្រឡេកមើលមកក្រោយ ឃើញភ្លើងឆេះផ្ទះតាចាស់ក៏នាំគ្នារត់មកជួយលត់ភ្លើង ។ ក្នុងវេលាដែលគេកំពុងតែរត់មកនោះ ស្រាប់តែទឹកសមុទ្រជោរមកដល់ប្រផុត ។ អ្នកទាំងនោះៗ រត់ស្ទើរតែមិនទាន់ ។ អ្នកចាប់ក្ដាមកាលជួយលត់ភ្លើងរលត់ហើយ ក៏សួរតាចាស់ថា "នែតា! ហេតុអ្វីបានជាភ្លើងឆេះផ្ទះតា?" ។ តាចាស់ប្រាប់ថា "ឥតហេតុអ្វីទេ ខ្ញុំដុតផ្ទះរបស់ខ្ញុំដើម្បីឲ្យពួកអ្នករត់ត្រឡប់មកវិញ កុំឲ្យលង់

ទឹកជំនន់ស្លាប់" ។ អ្នកចាប់ត្រីមទាំងអស់បានដឹងថាខ្លួនរួចរស់ជីវិតដោយសារតាចាស់គំរក្រៃពេកអរណាស់ ទឹករលឹកគុណតាចាស់មិនភ្លេចដោយឃើញថា តានេះជាមនុស្សមានចិត្តសប្បុរសល្អ ព្រោះតែគាត់ចង់ជួយសង្គ្រោះពួកយើង ទើបសុខចិត្តដុតផ្ទះរបស់ខ្លួនពោលមិនស្តាយ ។

រឿងនេះ បានគតិថាអ្នកដែលជួយសង្គ្រោះដោះទុក្ខធុរៈគេ ត្រូវតែជាអ្នករិះគិតឲ្យយ៉ាងល្អិតជ្រាលជ្រៅ ហើយចុះប្រសប់ខាងការជួយគេឲ្យបានរួចពីទុក្ខភ័យផង កុំឲ្យខ្លួនមានទុក្ខទោសផង ។

## ២.— រឿងអ្នកសុខចិត្តលះបង់ប្រយោជន៍តិចដើម្បីយកប្រយោជន៍ច្រើន

មានស្រ្តីជាតំយីពូនម្នាក់ ជាអ្នកមានធនធានស្តុកស្តម្ភ ។ នាងនេះមានចានយ៉ាងល្អ ១២ ជាទីស្រឡាញ់បំផុតចិត្ត ។ ថ្ងៃមួយមានខ្ញុំស្រីម្នាក់ធ្វើឲ្យបែកចាននោះមួយ ។ នាងម្ចាស់ចានខឹងណាស់ អត់មិនបានក៏យកកាំភ្លើងបាញ់ខ្ញុំស្រីនោះស្លាប់ភ្លាមទៅ ។ ពេលនោះ ទាហានម្នាក់បានដឹងរឿងនេះ ក៏ស្ម័គ្រប្រថុយកាត់ចិត្តចូលទៅនិយាយនឹងស្ត្រីម្ចាស់ចាននោះថា "សូមជំរាបអ្នកស្រី ! ខ្ញុំចេះផ្សាចានដែលបែកនោះឲ្យជាប់គ្នាស្អិតដូចដើមវិញបាន ប៉ុន្តែឲ្យខ្ញុំសុំមើលចានដែលនៅសល់ទាំង ១១ នោះសិនដើម្បីនឹងផ្សាចានបែកនោះឲ្យត្រូវធុនគ្នាកុំឲ្យខុសពីគ្នា" ។ ស្ត្រីម្ចាស់ចានឮដូច្នោះត្រេកអរណាស់ ចូលទៅលើកយកចានទាំង ១១ មកហុចឲ្យ

ទាហាន១ ទទួលយកមកហើយក៏លើកចានទាំង ១១ នោះបោកបោលទៅលើគ្គារ នៅចំពោះមុខនាងនោះ ។ ឯចានក៏បែកខ្ទេចទាំងអស់ឥតសល់ ១ឡើយ បោករួចប្រាប់ថា "សូមអ្នកស្រីយកកាំភ្លើងមកបាញ់សម្លាប់ខ្ញុំឥឡូវនេះចុះ ព្រោះដំឡៃចាន ១ នេះអ្នកស្រីសម្លាប់ជីវិតមនុស្សម្នាក់ដែរ ឥឡូវនៅសល់ចាន ១១ ទៀតនេះ មុខជាអ្នកស្រីសម្លាប់ជីវិតមនុស្សអស់ ១១ អ្នកទៀត ដោយហេតុនេះបានជាខ្ញុំដាច់ចិត្តយកជីវិតខ្លួនខ្ញុំមួយមកប្តូរស្លាប់ជំនួសជីវិតមនុស្សទាំង ១១ នាក់ ។

ស្ត្រីម្ចាស់ចានឃើញចានបែកខ្ទេចទាំងអស់ ហើយឮសំដីទាហាននិយាយប្រាប់ដូច្នោះ ក៏ភ្ញាក់ខ្លួនព្រើត ព្រឺព្រួចស្លុតចិត្តជាយ៉ាងខ្លាំងទាល់តែដួលសន្លប់នៅកន្លែងនោះ លុះនាងមានស្មារតីឡើងវិញហើយក៏គ្មានចិត្តខឹងទឹងទាហានសោះ លែងនឹកស្តាយចាននឹងរបស់ទ្រព្យទាំងពួងខុសទំនងដូចមុនទៀត មិនចាប់ទោសទាហាននោះឡើយ ។

រឿងនេះ បានគតិថា អ្នកមានគំនិតប្រាជ្ញាបានពិចារណាឃើញប្រយោជន៍យ៉ាងធំទូលាយទៅខាងមុខហើយ សុខចិត្តលះបង់ប្រយោជន៍តិចផ្ទាល់ខ្លួនចេញ សូម្បីជីវិតខ្លួនស្លាប់ក៏មិនស្តាយ គិតតែធ្វើឲ្យបានកើតផលប្រយោជន៍យ៉ាងធំទូលាយជាសាធារណៈដល់មនុស្សទូទៅ ។

## ៣.— រឿងអ្នកបិត្តផ្ទង់

នៅប្រទេសអល្លឺម៉ង់មានមេទ័ពជាតិអល្លឺម៉ង់ម្នាក់ឈ្មោះប៊ិស្មាក ជាមនុស្សកាចឃោរឃៅណាស់ ។ ថ្ងៃមួយ លោកប៊ិស្មាកមានជម្ងឺឈឺ

ប្រើបំរើឲ្យទៅហៅគ្រូពេទ្យម្នាក់មក ព្យាបាលរោគលោក ។ គ្រូពេទ្យមកដល់សួរលោកមេទ័ពថា "លោកឈឺត្រង់ណាខ្លះ?" ។ លោកបិស្មាកមិនឆ្លើយប្រាប់ថាឈឺអ្វីសោះ សូម្បីគ្រូពេទ្យសួរប៉ុន្មានដង លោកក៏ចេះតែសម្ងំស្ងៀមឈឹង ។ ទើបគ្រូពេទ្យជំរាបលោកមេទ័ពថា "ជម្ងឺរបស់លោកនេះ មានតែគ្រូពេទ្យសត្វទើបចេះមើល ឯគ្រូពេទ្យមនុស្សដូចជារូបខ្ញុំនេះ មើលជម្ងឺលោកមិនបានទេ" ថាយ៉ាងនេះហើយក៏លាលោកមេទ័ពចេញទៅដល់របងមុខផ្ទះ ។ លោកមេទ័ពឲ្យបំរើទៅតាមហៅគ្រូពេទ្យនោះមកវិញហើយសួរថា "អម្បាញ់មិញអ្នកនិយាយដូចម្តេច?" ។ គ្រូពេទ្យក៏ជំរាបតាមសំដីដើម ។ លោកមេទ័ពត្រដូះបោះហើយ ក៏ពេញចិត្តនឹងចំឡើយរបស់គ្រូពេទ្យនោះយ៉ាងក្រៃលែង ឥតប្រកាន់ទោសទងតបនឹងគ្រូពេទ្យនោះវិញសោះ ។

រឿងនេះ បានគតិថា អ្នកដែលមានបុណ្យស័ក្តិជាធំ ជាអ្នកត្រួតត្រាលើគេ ត្រូវតែមានចិត្តនឹងធឹងធ្ងន់ធ្ងរ មិនត្រូវឆាប់ច្រលោតខឹងនឹងអ្នកតូចទាបជាងខ្លួនដោយឥតពិចារណាទេ ។

## ៤.— រឿងអ្នកភិតភ័យដោយគំនិតស្មានខុស

មានអ្នកដំណើរពីរនាក់ ជាជាតិអ្វី នៅស្រុកទេសណា មិនដឹងប្រាកដ បានធ្វើដំណើរទៅប្រទេសដទៃ លុះដើរទៅដល់ភូមិមួយ ក៏ចូលទៅសូមផ្ទះបុរសប្តីប្រពន្ធដេក ១ យប់ ទំរាំតែភ្លឺនឹងចេញដំណើរទៅ

មុខទៀត ។ អ្នកម្ចាស់ផ្ទះក៏ទទួលដោយរាក់ទាក់ហៅអ្នកដំណើរទាំងពីរនាក់នោះឱ្យចូលទៅក្នុងផ្ទះហើយឱ្យអង្គុយនៅក្នុងបន្ទប់មួយ ។ អ្នកដំណើរបានគយគន់មើលឃើញមានកាំបិត, ប៉ូថៅ, ដាវ, ធ្នូ, ស្នា, និងកាំភ្លើងវែងខ្លីដែលគេតម្រង់រៀបគ្នានៅជញ្ជាំងក្នុងបន្ទប់នោះ ។ អ្នកដំណើរទាំងពីរនាក់នឹកព្រួយបារម្ភថា ផ្ទះនេះប្រហែលជាកន្លែងស្លាប់របស់យើងទេដឹង? គិតព្រួយចិត្តភិតភ័យណាស់ ទាល់តែសាបមាត់បរិភោគបាយមិនឆ្ងាញ់ ។ លុះរួចបាយហើយ ម្ចាស់ផ្ទះសួរអ្នកដំណើរថា ពេលព្រឹកស្អែកនេះ អ្នកនឹងអញ្ជើញទៅស្រុកណាទៀត?

អ្នកដំណើរតបថា «ខ្ញុំនឹងទៅភូមិគេខាងមុខឯណោះ» ។

ម្ចាស់ផ្ទះថា «បើដូច្នោះ សូមអ្នកកុំប្រញាប់ប្រញាល់ទៅពីព្រលឹមពេក សូមបង្អង់ចាំខ្ញុំធ្វើអាហារឱ្យដាក់ទៅតាមផ្លូវដ្បិតភូមិនោះនៅឆ្ងាយក្រែងអត់បាយកណ្ដាលផ្លូវ» ប្រាប់រួចហើយក៏ឱ្យអ្នកដំណើរទាំងពីរនាក់ឡើងទៅដេកលើស្ពាកតូបមួយក្នុងផ្ទះ ។

ឯអ្នកដំណើរម្នាក់នៅក្មេងសេចក្ដី ឥតគិតខ្វាយអ្វីសោះ ចេះតែដេកលក់ស្រមុកខ្ទរទាល់ភ្លឺទៅ ។ ចំណែកអ្នកដំណើរម្នាក់ទៀតជាមនុស្សចាស់សេចក្ដី មានគំនិតល្អិតល្អន់ ចេះតែគិតរំពឹងដល់គ្រោះថ្នាក់ក្រែងកើតមានមកដល់ខ្លួន ពេលដេកគាត់មិនហ៊ានទុកហិបស្បៀងឱ្យឆ្ងាយពីខ្លួនគាត់ទេ គាត់យកហិបនោះកើយជំនួសខ្នើយ ហើយគាត់ព្រួយបារម្ភ

ណាស់ ដេកមិនលក់តាំងពីពេលព្រលប់រហូតដល់ពេលមាន់រងាវជិតភ្លឺ ស្រាប់តែគាត់ឮសូរស្រិបៗ នៅខាងក្រោមដំណេកខ្លួន គាត់កិតភ័យខ្លាំងណាស់ ខំសម្លឹងមើលទៅតាមចំពង់ភ្លើងជើងក្រាន ឃើញប្រពន្ធកាន់កាំបិតធំ ១ ប្ដីកាន់ប៉ូវថៅ ១ ហើយឮសូរប្ដីខ្សឹបខ្សាវៗ សួរប្រពន្ធថា "យើងសម្លាប់ទាំងពីរឥឡូវនេះទៅឬអី ឬក៏សម្លាប់តែ ១ ទុក ១ សិន?" ។ ឯអ្នកដំណើរគ្រាន់តែបានឮពាក្យប៉ុណ្ណោះហើយ ក៏ស្លុតចិត្តបាត់វិញ្ញាណ ត្រជាក់ខ្លួនដូចសម្រឹទ្ធិ គិតថា "ឱ! ជីវិតអញនៅក្នុងកណ្ដាប់ដៃអ្នកទាំងពីរនេះហើយ មិនដឹងគិតធ្វើម្ដេចនឹងឲ្យបានរួចជីវិតទេ អញនឹងដាស់សំឡាញ់ម្នាក់នេះឲ្យភ្ញាក់ឡើង ខ្លាចក្រែងវាមាត់ឡេឡាស្រែកទ្រហោយំឲ្យឮដល់គេឯង បើអញនឹងលោតចុះទៅតាមបង្អួចៗនេះខ្ពស់ឆ្ងាយពីដីណាស់ មួយទៀត នៅឯដីមានឆ្កែធំៗ សុទ្ធតែកាចសាហាវនៅជុំវិញផ្ទះផង អញនឹងរត់ទៅណាក៏មិនរួចពីមាត់ឆ្កែទាំងនោះដែរ ណ្ហើយចុះ បើដូច្នោះគួរតែអញសម្ងំឲ្យស្ងៀមចាំសង្កេតមើលហេតុគេទសិន" ។ អ្នកដំណើរកំពុងតែជញ្ជឹងគិតយ៉ាងនេះ ស្រាប់តែឮសូរជើងឡើងជណ្ដើរថ្នមៗ គ្រឹបៗ មក ពេលនោះព្រលឹងរបស់អ្នកដំណើររត់ចេញបាត់ពីខ្លួនអស់រលីង ។ បន្តិចមកទៀត គាត់ឮសូរសន្ទឹកទ្វារក្រឹតៗ ដែលគេច្រានសន្សឹមៗ គាត់រឹតតែតក់ស្លុតខ្លាំងណាស់ គិតរកផ្លូវដោះខ្លួនមិនឃើញសោះ ក៏នឹកថា "ឱ! ជីវិតអញមុខជាស្លាប់ពេលនេះពិតប្រាកដហើយ" ។ គាត់គិតស្មានយ៉ាងនេះរួច

ខំសម្ងំដេករឹងខ្លួនស្ងួកលែងហ៊ានកំរើក គ្រាន់តែបើកភ្នែកព្រឹមៗ ចាំលបមើល ស្រាប់តែគាត់ឃើញបុរសម្ចាស់ផ្ទះលូកដៃទៅចាប់មាន់ក្រៀវមួយគូដែលវាដេកលើផ្នើរក្បែរស្លាកនោះបានហើយយកចុះបាត់ទៅ ។ អ្នកដំណើរឃើញច្បាស់ដូច្នោះហើយ ក៏ត្រេកអរព្រួចទឹកអស់សំណើចតែក្នុងចិត្តម្នាក់ឯងថា “ឱ! ពុទ្ធោ! អញភិតភ័យដោយគិតស្មានខុសស្រឡះទេតើ” ។

លុះដល់ព្រឹកឡើង អ្នកដំណើរទាំងពីរនាក់ចូលទៅលាម្ចាស់ផ្ទះនឹងចេញដើរទៅទៀត ។ អ្នកម្ចាស់ផ្ទះយកមាន់ឆ្អិនស្រុបទាំងពីរនោះមកប្រគល់ឲ្យអ្នកដំណើរហើយប្រាប់ថា “មាន់ ១ នេះចូរអ្នកបរិភោគឥឡូវនេះទៅ ឯមាន់ ១ ទៀតចូរអ្នកដាក់យកទៅទុកបរិភោគតាមផ្លូវ ក្រែងអ្នកទៅយឺតយូរ ក្រទៅដល់ស្រុកគេឯណាយ” ។ អ្នកដំណើររីករាយសប្បាយចិត្តណាស់ ទទួលយកមាន់ទាំង ២ រួចសំពះលាម្ចាស់ផ្ទះចេញដំណើរទៅទៀត ។

រឿងនេះបានគតិថា បើកាលណាយើងមិនទាន់បានដឹងហេតុការណ៍ច្បាស់លាស់ទេ យើងមិនត្រូវភិតភ័យតក់ស្លុតដោយគំនិតគិតស្មានទុកជាមុនឡើយ យើងត្រូវតែចាំសង្កេតមើលហេតុភេទនោះៗ ឲ្យដឹងជាក់លាក់សិន បើយើងចេះតែភ័យខ្លាចឥតគំនិតទៅ នឹងនាំឲ្យមានទុក្ខទោសដល់ខ្លួនជាមិនខាន ។

# ការបណ្ដុះនិស្ស័យ

## ព្រះមហាឧត្ដមវិជ្ជា ផលញ្ញាណោ ប៉ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណាគាររក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

---

ង) បណ្ដុះនិស្ស័យជឿខ្លួនឯងដោយការសន្ទនាប្រស្រ័យ ក្នុងការសន្ទនាគ្នា ចូរមានចិត្តគំនិតដែលបរិសុទ្ធច្បាស់លាស់ទឹងធឹង ទឹងស្មោះត្រង់ ៗ កាលបើគិតនឹងនិយាយពាក្យយ៉ាងណាដែលគួរនិយាយ ចូរនិយាយពាក្យយ៉ាងនោះនិយាយតាមសេចក្ដីពិត, និយាយដោយអាងហេតុផលជានិច្ច, ជៀសវាងការគ្រោធខឹងត្រូវទារវេនគ្នា, ចរចាដោយរីករាយបរិសុទ្ធជាមួយនឹងគូសន្ទនា, ស្ដាប់អ្នកដទៃនិយាយដោយយកចិត្តទុកដាក់, មិននិយាយកាត់រឿងគេក្នុងកាលដែលគេកំពុងនិយាយ, ត្រូវស្ដាប់ឲ្យចូលចិត្តច្បាស់លាស់ក្នុងពាក្យសំដីរបស់អ្នកដទៃ, មិនឃើញតែសេចក្ដីអាក្រក់របស់អ្នកដទៃ, មិនសរសើរគេតែក្នុងទីចំពោះមុខ, មិននិន្ទាគេតែក្នុងទីកំបាំងមុខ ទឹងចូរប្រើសំដីសុភាព កុំប្រើពាក្យគ្រោតគ្រាតបែបមនុស្សថោកទាប កុំនិយាយត្រឡប់ត្រឡិនរកតែគេជឿមិនបាន, កុំជាមនុស្សមាត់ស្រួចដើរចាក់រុកញុះញង់គេឬយករឿងពីឯណោះទៅរកឯណេះ យករឿងពីឯណោះមកឲ្យឯណេះ, កុំជាមនុស្សមាត់ដាច

លាក់រឿងកំបាំងទុកមិនជិត ទឹងកុំជាមនុស្សនិយាយឡេះឡោះត្រឡប់ត្រឡិនទាល់តែទ្រាន់ត្រចៀកស្តាប់មិនបាន ទាំងមិនមានសារប្រយោជន៍អ្វីមួយនោះឡើយ ។

ច ) បណ្តុះនិស្ស័យៈជឿខ្លួនឯង ដោយការជឿកម្មជាច្បាប់ធម្មតាដែលទៀងទាត់, ជាគ្រាប់ នៃសម្ពន្ធកម្មរវាងពួកសត្វក្នុងកំណើតផ្សេងៗ, ជារបស់ទៀងទាត់ជានិច្ច គឺអ្នកណាមួយធ្វើអំពើណាហើយមិនដែលប្រែប្រួលទៅចាកផលនៃអំពើនោះឡើយ ។ បើចង់កុំឲ្យមានគំនិតអាក្រក់ទឹងគំនិតថោកទាប ត្រូវកុំភ្លេចច្បាប់នេះឲ្យសោះ សូម្បីលោក-អ្នកសង្ស័យថា ដូងផ្កាយអាចក្លាយទៅជាភ្លើងបាន ព្រះអាទិត្យអាចប្រែប្រួលទៅជាអ្វីបាន, សេចក្តីពិតអាចក្លាយទៅជាសេចក្តីមិនពិតវិញបានក៏ដោយ ក៏កុំសង្ស័យក្នុងកម្មរបស់ខ្លួនឯង ដែលខ្លួនបានធ្វើមកហើយថានឹងអាចក្លាយទៅជាយ៉ាងដទៃនោះឡើយ ចូរជឿឲ្យជាក់ថាយើងមានកម្មជារបស់ខ្លួន, មានកម្មជារបស់អំណោយផល, មានកម្មជាកំណើត, មានកម្មជារបស់ជាប់ទៅតាម មានកម្មជាទីពឹងពាក់អាស្រ័យ, បើធ្វើកម្មល្អ ត្រូវបានទទួលផលល្អ, បើធ្វើកម្មអាក្រក់ផលអាក្រក់ត្រូវតាមសងមកវិញ ។ ព្រោះគុនសារគឺផលរបស់កម្មក្នុងកាលមុននោះ មិនសាបសូន្យទៅណាឡើយ ត្រូវអណ្តែតឡើងត្រូវបក្សីដែលហោះនៅលើមេឃ ត្រូវចុះតាមមកត្រូវពួកសត្វដែលនៅលើផែនដី ត្រូវត្រឡប់ចុះទៅ

ត្រូវដុះខ្ទង់ផែលនៅក្នុងដី · ទឹងត្រូវផែកទឹកចុះទៅត្រូវហ៊ូងត្រី ក្នុងផ្ទៃមហាសមុទ្រ (នេះជាពាក្យប្រៀបធៀបឲ្យឃើញកម្លាំងរបស់ផលនៃកម្ម) ។

ដោយសារតែមាននិស្ស័យជឿខ្លួនឯងនេះជាហេតុហើយ បានជាលោក-អ្នកអាចយកឈ្នះការងារបានគ្រប់យ៉ាង ទោះបីការងារនោះលំបាកយ៉ាងណាក៏ដោយ ទាំងធ្វើឲ្យអ្នកនៅក្រោមបង្គាប់បញ្ជាជឿទុកចិត្តប្រាកដឡើងផង ឬសូម្បីលោក-អ្នកនៅក្រោមបង្គាប់បញ្ជារបស់អ្នកដទៃ ក៏អាចនៅបានយ៉ាងស្រួល ព្រោះលោកជាប្រធានមិនបាច់លំបាកចិត្តអ្វីឡើយ មិនបាច់អង្វរករណែនាំញយៗពេក ទាំងមិនបាច់ចាំឈរមើលឲ្យឃើញថា លោក-អ្នកធ្វើការសម្រេច ឬមិនសម្រេចឡើយ ។ សូម្បីអ្នកដទៃ ក៏គង់ជឿប្រាកដ ចំពោះខ្លួនលោក-អ្នកបានថា ទោះបីលោក-អ្នកមិនមានទ្រព្យសម្បត្តិ មិនមានអំណាចបុណ្យស័ក្តិ អាចទីងលើកដំកើងឋានៈរបស់គេឲ្យអណ្តែតបាន ក៏គង់អាចធ្វើការងារឲ្យដល់មិត្តភក្តិក្រុមជាតិបានល្អ ជាងមនុស្សដែលកើតមកប្រកបព្រមដោយទ្រព្យសម្បត្តិ និងអំណាចជាតិត្រកូល តែខ្វះការជឿខ្លួនឯងនោះទៅទៀត ។

៤ — ចេះពិចារណាខ្លួនឯង គោលសំខាន់ពិតប្រាកដនៃការកេប់កានខ្លួនរបស់យើង នៅត្រង់ការចេះពិចារណាខ្លួនឯង ត្រូវតាមខ

សេចក្ដីដែលដកចេញមកអំពីពុទ្ធភាសិតមួយបទថា "លោក-អ្នក ប្រពិចារណាខ្លួនដោយខ្លួនឯង" ។ គោលនេះចាត់ថាជាមូលហេតុនៃសេចក្ដីសម្រេចកិច្ចទាំងឡាយ ទាំងជាគ្រឿងនាំជីវិតរបស់យើងឲ្យឈានទៅមុខយ៉ាងរីកពាយផុតភ័យ បានសេចក្ដីក្សេមក្សាន្តសុខសប្បាយរហូតដល់ត្រើយ ។ បុរាណពោលថា "ពុកមាត់ធ្មាជាមគ្គុទ្ទេសក៍របស់ធ្មា, ការពិចារណាខ្លួនឯង ក៏ជាផ្លូវដំណើរដ៏ចំរើនរបស់ខ្លួនដែរ" ។ ពិតមែនមនុស្សដែលពប់ការខ្លួនឯង បើធ្វើការអ្វី ក៏ត្រូវតាមគោលដែលគួរធ្វើសមគួរដល់អំពើរបស់មនុស្ស ទាំងឋានៈរបស់ខ្លួន មិនធ្វើការអ្វីដែលខុសចាកគោលដ៏គួរ ដែលជាអំពើថោកទាប ជាងអំពើរបស់មនុស្ស ទាំងឋានៈរបស់ខ្លួនឡើយ ធ្វើតែការងារដែលត្រូវតាមគន្លងសីលធម៌ ឬត្រូវតាមគន្លងច្បាប់ ដែលបើកឲ្យធ្វើហើយមិនជាការក្ដៅក្រហាយដល់មនុស្សដទៃផង ព្រមទាំងជាអំពើត្រូវតាមគន្លងនីតិធម៌របស់ប្រជាជនច្រើនគ្នា ហើយមុននឹងធ្វើ តែងមានការព្យាយាមត្រួតត្រាពិនិត្យខ្លួនឯងដោយប្រយ័ត្នប្រយែងជានិច្ច ។

ការរៀនឲ្យស្គាល់ខ្លួនឯង ជាលក្ខណៈនៃការចេះត្រួតត្រាពិនិត្យខ្លួនឯង ។ យើងបញ្ចេញកំឡាំងសម្រាប់កាយ, យើងពិចារណាត្រួតត្រាខ្លួនឯងសម្រាប់ចិត្ត ដើម្បីឲ្យកើតអនាម័យល្អ ។ ការបញ្ចេញកំឡាំងជាអនាម័យរបស់កងកាយ ធ្វើឲ្យយើងមានកំឡាំងរឹងប៉ឹង ។ ការ

ពិចារណាត្រួតត្រាខ្លួនឯង ជាអនាម័យរបស់ចិត្ត ធ្វើឲ្យយើងមានជីវិតជាខ្ទឹមសារ ៗ បុរាណចងសុភាសិតទុកថា "អ្នកដែលស្គាល់ជំរៅរបស់ទន្លេ គឺទន្លេ, អ្នកដែលស្គាល់ទំហំរបស់អាកាស គឺអាកាស, ឯអ្នកដែលស្គាល់ល្អស្គាល់អាក្រក់ក្នុងខ្លួនបាន ក៏គឺខ្លួនរបស់យើងហ្នឹងឯង" ។ ដូច្នេះ មនុស្សដទៃ សព្វទាំងផែនដី បើទុកជាយើងមិនដឹង ក៏មិនជាអ្វីដែរ តែត្រូវការដឹងស្គាល់ខ្លួនឯងនេះ ចូរកុំភ្លេចឲ្យសោះ ។ ព្រោះការរៀនឲ្យស្គាល់ខ្លួនឯងនេះ លំបាកក្រៃលែងជាងការរៀនឲ្យស្គាល់មនុស្សដទៃទៅទៀត តែសព្វយ៉ាងនោះក៏ជារឿងដែលត្រូវរៀនឲ្យស្គាល់ខ្លួនឯងមុនជាងស្គាល់អ្វីៗ ទាំងអស់ ។ ព្រោះថាអ្នកដែលមានស្មារតីតែងមិនខុស, អ្នកប្រយ័ត្នខ្លួនតែងមិនខូចចិត្ត, អ្នកប្រឹងប្រែងព្យាយាមតែងមិនអត់ឃ្លាន, អ្នកឃើញកំហុសរបស់ខ្លួន ដោយការពិចារណាត្រួតត្រាខ្លួនឯង រមែងខ្លាចរអាចំពោះការមិនពិចារណា, អ្នកដែលចេះឈឺចិត្តព្រោះឃើញកំហុសរបស់ខ្លួន តែងប្រែត្រឡប់ទៅជាមនុស្សល្អវិញបាន ដោយការប្រយ័ត្ននឹងការដឹងខ្លួនទាន់នោះ, អ្នកព្យាយាមយកខ្លួនរបស់ខ្លួនមកពិចារណាត្រួតត្រាទូន្មានខ្លួនឯងថា អំពើណាគួរធ្វើ សំដីណាគួរនិយាយឬគួរនិយាយក្នុងកាលណា គួរស្ងៀមមាត់ក្នុងកាលណា នឹងអារម្មណ៍ណាគួរនឹករឭកនោះ កាលបើជួបប្រទះនូវហេតុទាំងអម្បាលនេះហើយ អាចផុតចាកសេចក្តីទាក់ទាមនឹងរឿងពិរុទ្ធ

ទាំងពួងបាន ទាំងមិនកើតជម្លោះវិវាទបែកបាក់គ្នា ឬត្រូវទោសទុក្ខវិនាសចលចលង់ទៅខាងមុខផង ។

អំពើ, សំដីនិងគំនិត ជារបស់សំខាន់ដោយមុខ ៗ តែដែលជារបស់សំខាន់បំផុត គឺការពិចារណាត្រួតត្រាខ្លួនឯង ទាំងក្នុងវេលាកំពុងគិត កំពុងធ្វើឬកំពុងនិយាយ, ចំណុចនៃការពិចារណាត្រួតត្រាខ្លួនឯងនៅត្រង់ការធ្វើ, ការនិយាយ និងការគិតរបស់ខ្លួន ទាំងក្នុងផ្នែកការងារ ផ្នែកការសិក្សា ផ្នែកការប្រព្រឹត្ត រហូតដល់ផ្នែកនៃការស្គាល់ជំនាញនិងសមត្ថភាព ។ កាលយើងពិចារណាត្រួតត្រាខ្លួនឯង ដោយន័យនេះហើយ យើងអាចស្គាល់ខុសស្គាល់ត្រូវ អាចប្រព្រឹត្តខ្លួនឲ្យសមគួរល្មមមើល មិនខ្ពស់ពេកមិនទាបពេកបាន អាចសង្កេតឃើញបាន នូវសេចក្ដីខ្វះខាត ឬសេចក្ដីពេញលេញល្អ, វៀងពិរុទ្ធនិងវៀងបរិសុទ្ធរបស់ខ្លួនក្នុងផ្នែកនោះ ៗ ព្រោះការដឹងខុសនិងត្រូវនេះ ជាបច្ច័យឲ្យស្គាល់ខ្លួនឯងស្គាល់ឋានៈរបស់ខ្លួន និងបេះពិតគិតក្សាអ្នកមានឋានៈខ្ពស់មិនឲ្យធ្លាក់មកទាប លើកស្ទួយអ្នកមានឋានៈទាបឲ្យខ្ពស់ឡើងទៅតាមលំដាប់នាំទៅកាន់ការរុងរឿងស្ថាពរ និងការវិវឌ្ឍនាការជាស្ថាពរក្នុងវេលាខាងមុខ នាំឲ្យផុតចាកសេចក្ដីល្ងង់ខ្លៅដែលជាចំរូងយ៉ាងមុតក្រៃលែងចំពោះអ្នកនាំយកទៅទុកក្នុងខ្លួន ។

ចបស័គ្គដែលនាំកំពង់ពន្លករណាផ្លូវនោះ គឺសេចក្ដីល្ងង់ខ្លៅ ។ លោកអ្នកមិនត្រូវមើលមនុស្សដទៃឲ្យច្រើនជាងមើលខ្លួនឯងឡើយ បើ

មិនដូច្នោះទេ ខឹងត្រូវដំនៀលថាខ្លួនល្អ ។ គប្បីនឹកផងថា មនុស្សល្អបំផុតក្នុងចំណោមមនុស្សទាំងអស់នោះ គឺមនុស្សដែលចូលចិត្តស្វែងរកសេចក្តីល្អនៃមនុស្សដទៃ មកផ្សំបំពេញនឹងសេចក្តីល្អរបស់ខ្លួនឯងដែលមានស្រាប់ហើយ ។ មនុស្សល្អនោះ ក្នុងវេលាត្រូវដំនៀល ឬបានទទួលពាក្យសរសើរ រមែងជាមនុស្សមិនស្គាល់ខុស-ត្រូវ ច្រើនរឹងត្អឹង ប្រកាន់ខឹងចំពោះពាក្យដំនៀលក្នុងកាលដែលខ្លួនត្រូវដំនៀល នឹងរីករាយចិត្តក្នុងពាក្យសរសើរ ដែលគេសរសើរខ្លួន ទោមនស្សតូចចិត្តក្នុងពាក្យដំនៀល ក្អើតក្អើនក្នុងពាក្យសរសើរ កាលបើក្អើតក្អើនខ្លាំងក៏វង្វេង កាលបើវង្វេងក៏ល្មើស បើល្មើសហើយ ក៏ខូចមនុស្សធម៌ ។

មនុស្សល្អច្រើនតែមានភ្នែកខ្វាក់ ក្នុងក.រខ្ជិារបស់ខ្លួន ហើយមានភ្នែកភ្លឺក្នុងកំហុសរបស់មនុស្សដទៃ ចូលចិត្តមើលមនុស្សដទៃពេញរង្វង់ភ្នែក មើលខ្លួនឯងដោយកន្ទុយភ្នែក កំហុសរបស់អ្នកដទៃ សូម្បីតូចប៉ុនគ្រាប់ស្ពៃក៏ឃើញបានងាយ កំហុសរបស់ខ្លួនវិញ សូម្បីប៉ុនដូងទាំងសំបក ក៏មើលមិនងាយឃើញ ព្រោះចូលចិត្តចង់ដឹង ចង់ឃើញតែទោសរបស់អ្នកដទៃ ឯទោសខ្លួនវិញ ចូលចិត្តធ្វើព្រងើយកន្តើយ មិនអើពើឡើយ ខំតែបិទទុក សូម្បីបិទទុកហើយមិនជិត ក៏សម្គាល់ថាកំហុសខ្លួនមិនធ្ងន់ប្រហែលនឹងកំហុសអ្នកដទៃ ត្រឡប់ជាដំកើងខ្លួនថាគ្រាន់បើជាងមនុស្សដទៃទៅវិញថែមទៀត ចូលចិត្តបាចសាចទោសគេ

ដូចជាបាចសាចអង្កាម  សូម្បីមិនមានគេសួរក៏ដោយ,  តែឯគុណគឺសេចក្ដីល្អរបស់គេវិញ សូម្បីមានគេសួរ ក៏មិនពណ៌នាឲ្យដល់ ឯទោសរបស់ខ្លួន ខ្លួនបិទទុកឲ្យជិត ដូចជាអណ្ដើកលាក់ក្បាលទឹងជើងទុកក្នុងស្នូក សូម្បីត្រូវគេសួរ ក៏និយាយបញ្ចៀសវាសវាងបន្ថែមបន្ថយឲ្យបាត់ទៅ គុណរបស់ខ្លួនវិញ សូម្បីមិនមាននរណាសួរ ក៏និយាយកោរកោរព្រោកប្រាជ្ញទៅ នេះឯងជាទោសនៃការមិនបេះពិចារណាត្រួតត្រាខ្លួនឯង ។

ដូច្នេះ យើងទើបគួរបេះពិចារណាត្រួតត្រាខ្លួនឯងឲ្យណាស់ បើយើងមិនមានទោសកំហុសក្នុងខ្លួនឯងទេ ទឹងតិះដៀលមនុស្សដទៃដើម្បីដាស់តឿនខ្លះក៏គួរ តែបើយើងមានទោសកំហុសពេញទាំងខ្លួនត្រឡប់ទៅតិះដៀលគេវិញ ក៏ជាហេតុទាក់ទុកឲ្យគេសើច - ចំអកមកវិញបាន ។ យើងមុនទឹងតិះដៀលគេនោះ គប្បីពិនិត្យមើលទោសខ្លួនឯងឲ្យសព្វគ្រប់សិន ទឹងគប្បីត្រួតមើលខ្លួនឯងឲ្យច្រើន ដោយប្រៀបធៀបទឹងអ្នកដទៃ ព្រោះបើគេធ្វើខុស ប្រាប់ឲ្យយើងដឹងថាគេធ្វើខុស តែពេលដែលយើងធ្វើខុសវិញ ក្រៅពីខ្លួនឯងហើយ មិនមាននរណាប្រាប់ថាយើងធ្វើខុសទេ ទើបឃើញថា មិនមានដំណើងណាក្នុងលោកដែលមានដំឡៃប៉ុនគ្នា ទឹងការបេះត្រួតពិនិត្យខ្លួនឯង ដោយការតិះដៀលខ្លួនឯងសង្កត់សង្កិនខ្លួនឯងនេះឡើយ ។ បើយើងចង់ជួយខ្លួនឯងឲ្យផុត

ចាកពាក្យពោលផ្ដាសាអំពីអ្នកដទៃផង គំរឹងរឹតតែត្រូវបង្អាក់ហ៊ឹកហ៊ឺនការត្រួតពិនិត្យខ្លួនឯង ឲ្យស្អាតជំនាញថែមទៀត ដូចជាក្នុងវេលាត្រូវជំទៀល ឬបានទទួលពាក្យសរសើរ បើយើងធ្លាប់ត្រួតពិនិត្យខ្លួនឯងជានិច្ចមកហើយ កាលពួកគេជេរៀល គំមិនក្រញេងក្រញាងប្រកាន់ខឹងចំពោះអ្នកជេរៀល កាលបើពួកគេសរសើរ គំមិនភ្លើតភ្លើនក្នុងពាក្យសរសើរនោះ ។

តាមពិត មនុស្សដទៃ មានទោសប៉ុន្មាននោះ មិនជារឿងអ្វីដែលយើងត្រូវស្វែងរកទេ ។ គោលយ៉ាងសំខាន់ក្រៃលែងនោះ នៅត្រង់យើងព្យាយាមត្រួតត្រាពិចារណាខ្លួនឯង ។ បើយើងត្រួតត្រាពិចារណាខ្លួនឯងច្រើនឡើងត្រឹមណា នឹងឃើញច្បាស់នូវសេចក្ដីល្ងង់ខ្លៅរបស់ខ្លួនឯងច្រើនឡើងត្រឹមនោះ ។ បើយើងរឹតតែឃើញច្បាស់ នូវសេចក្ដីល្ងង់ខ្លៅរបស់ខ្លួនឯងច្រើនឡើងត្រឹមណា គំរឹងរឹតតែស្គាល់ការខ្វះខាត នឹងការពិរុទ្ធដែលមាននៅក្នុងខ្លួន, ហើយកែខៃការខ្វះខាត នឹងការពិរុទ្ធរបស់ខ្លួនរឹតតែបានច្រើនឡើងត្រឹមនោះ ។ «មិនគួរយកចិត្តទុកដាក់នឹងពាក្យបាក់ដោតអាក្រក់ នឹងកិច្ចដែលធ្វើហើយ នឹងមិនទាន់ធ្វើរបស់ជនដទៃទេ គួរពិចារណាមើលតែកិច្ចដែលធ្វើហើយ នឹងមិនទាន់ធ្វើរបស់ខ្លួនប៉ុណ្ណោះជាការប្រសើរជាង» នេះជាពុទ្ធភាសិតសម្រាប់ខ្លួនយើង ។

(មានត)

# រឿងសាមកុក

## ភាគទី ១៨

### ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ទៀវពីតបថា កាលគ្រាតេងងួននឹងតាំងតុះស្លាប់នោះ លោកក៏គង់ផ្ទាបស្រាប់ហើយ ហេតុម្តេចត្រឡប់មកសួរចង់ដឹងចិត្តខ្ញុំធ្វើអ្វីទៀត ។ លីបោ៉ឮទៀវពីថាដូច្នោះក៏ខឹងណាស់ សំឡក់សំឡឹងទៀវពីដោយទឹកក្នាញ់ថា ទៀវពីនេះជាមនុស្សមិនដឹងគុណអញសោះ ៗ រួចក៏បង្គាប់ទាហានឲ្យនាំខ្លួនលីបោ៉ចេញទៅសម្លាប់ ៗ ខណៈកាលទាហានចូលទៅទាញយកខ្លួននោះ លីបោ៉ស្រែកដេរថា អាទៀវពីត្រចៀកយារ ! អាឯងមិនគិតដល់គុណអញសោះ កាលគ្រាគីឡេងនឹងធ្វើអន្តរាយវា កុំតែអញគិតកលឧបាយបាញ់ធ្នូឲ្យត្រូវបុងខ្លួន វាក៏មិនមែនរួចជីវិតទេ ឥឡូវវាត្រឡប់រមិលគុណអញវិញ ៗ ទទួលទាហានរួចចាប់ខ្លួនទៀវលៀវចង់នាំ .

មកទៀត ។ តៀវលៀវឮលីប៉ោថាដូច្នោះ ក៏និយាយនឹងលីប៉ោថា កើតមកជាជាតិទាហានហើយមិនត្រូវស្តាយជីវិតទេ បើត្រូវស្លាប់ក៏ស្លាប់ទៅចុះ ត្រូវចុះតែឈ្មោះឲ្យជាប់ក្នុងពង្សាវតារ ។ លីប៉ោបានស្តាប់តៀវលៀវថាដូច្នោះក៏ស្ងៀម ទាហានទាំងពួងក៏នាំខ្លួនលីប៉ោចេញទៅប្រហារជីវិត ហើយកាត់ក្បាលដោតនៅមុខទ្វារស្រុក ។

ទាហានក៏នាំខ្លួនតៀវលៀវឡើងលើសែនជួបនឹងចូឆ្ងូ ក៏ថា តៀវ-លៀវ! អ្នកឯងនេះមានរូបរាងមាំមួនសមជាសេនាទាហាន មួយទៀតៈយើងក៏នៅចាំថាអ្នកឯងនេះហើយដែលច្បាំងនឹងយើងម្តង ។ តៀវលៀវឆ្លើយថា កាលច្បាំងនៅស្រុកប៉ាក់អៀងនោះលោកភ្លេចទៅហើយឬ ខ្ញុំនៅគិតស្តាយពេកណាស់ ។ ចូឆ្ងូសួរថា អ្នកឯងស្តាយអ្វី? ។ តៀវលៀវតបថា ខ្ញុំស្តាយ កាលដុតស្រុកប៉ាក់អៀងនោះភ្លើងឆេះតិចពេក បើភ្លើងឆេះខ្លាំងប្រហែលស្លាប់អស់ត្រកូលសម្បត្តិឯងបាត់ទៅហើយ ។ ចូឆ្ងូបានឮដូច្នោះក៏បានសេចក្តីអាប់យសណាស់ ស្រែកថា "ខ្លួនអាឯងជាឈ្លើយ នឹងស្លាប់ជីវិតឥឡូវហើយ ហេតុម្តេចក៏ហ៊ាននិយាយទ្រគោះឲ្យអញដូច្នេះ" ថាហើយក៏ហូតក្រប៊ីគិតនឹងកាប់តៀវលៀវ ។ ក្នុងខណៈនោះតៀវលៀវក៏ឥតញញើតឱនកទៅឲ្យចូឆ្ងូកាប់ ។ ទទួលគួនអ៊ូចូលទៅហាមឃាត់ចូឆ្ងូហើយគំនាប់ថា ដែលលោកនឹងសម្លាប់តៀវលៀវនោះសុំឲ្យបង្អង់សិន ព្រោះតៀវលៀវជាមនុស្សសុចរិតពិតត្រង់ គួរចិញ្ចឹមរក្សាទុកឲ្យនៅធ្វើ

កជការជាមួយនឹងលោក  បើទៅមុខហើយតៀវលៀវត្រឡប់វៀចគិតប្រទូសរ៉ាយនឹងលោកវិញ  សុំឲ្យលោកកាត់ក្បាលខ្ញុំបាទចុះ ។

ចូឆូបានស្តាប់ដូច្នោះ ក៏មានសេចក្តីត្រេកអរឆ្លើយថា "យើងដឹងហើយគឺចិត្តតៀវលៀវនេះជាមនុស្សទៀងត្រង់ល្អណាស់  ដែលយើងធ្វើដូច្នេះប្រាថ្នានឹងពិសោធចិត្តតៀវលៀវលមើល  បើជាទាហានមែនទែនមិនខ្លាចស្លាប់ទេ  ឥឡូវយើងឃើញចិត្តតៀវលៀវជាមនុស្សមាំមួន  គួរចិញ្ចឹមរក្សាទុកតទៅបាន" និយាយហើយក៏ក្រោកទៅស្រាយចំណងតៀវលៀវចេញទាំងអស់  ហើយយកអាវយ៉ាងល្អឲ្យតៀវលៀវពាក់ហើយដឹកដៃទៅអង្គុយលើទីសមគួរ ។ តៀវលៀវមានចិត្តត្រេកអរក៏ឱនគំនាប់ហើយនិយាយថា  ដែលមហាឧបកដមានសេចក្តីករុណាទុកអាយុជីវិតខ្ញុំបាទឲ្យរស់នៅដូច្នេះ  ព្រះតេជព្រះគុណធំមិនមានទីបំផុត  ខ្ញុំបាទនឹងសុំនៅជួយធ្វើកជការនឹងលោកត្រាតែអស់ជីវិត ។ ចូឆូក៏តាំងតៀវលៀវជាចុង-ឡុងជៀង  គឺនាយទាហានទោ  ហើយក៏ចាត់ប្រើតៀវលៀវឲ្យទៅបញ្ចុះបញ្ចូលចុងប៉ាជាសេនាលីប៉ោ ។ ឯចុងប៉ាកាលបានដឹងដំណឹងថាលីប៉ោស្លាប់ហើយ  ឥឡូវតៀវលៀវចូលទៅនៅនឹងចូឆូដូច្នោះ  ចុងប៉ាក៏បបួលស៊ុនគួន ១, ង៉ុន ១, អ៊ុនខៀ ១ ចោរទាំង ៣ នាក់នេះ  នឹងពលទាហានទាំងពួងចូលទៅរកចូឆូឯស្រុកហៃហ៊ី  នៅតែសៀងហ៊ូរត់ទៅពីទីនោះបាត់ ។  ចូឆូឃើញចុងប៉ានឹងទាហាននោះមកក៏ទទួលរាក់ទាក់

រួសរាយណាស់ តាំងចុងប៉ាជានាយទាហានធំ ឯនាយទោរទាំង ៣ តាំងជានាយទាហានរង ហើយឲ្យលើកពលៈទៅគយល្បាតណាតកងក្រវែលដែនវែងត្រតាមមាត់សមុទ្រៈដើម្បីការពារសត្រូវ ។

ក្នុងសម័យនោះបុប្ផឲ្យរង្វាន់បំណាច់នាយកងនាយទ័ព នឹងពលទាហានធំតូចតាមសមគួរ ហើយឲ្យលើកនាំយកគ្រប់គ្រួលីប៉ោចូលទៅក្រុងហ្វូតោ ។ ឯបុប្ផក៏លើកទ័ពត្រឡប់ទៅស្រុកឈើជីរ អាណាប្រជានុកស្ត្រទាំងពួងជីងជូប៉ោះ ក៏តែងតុះតាំងគ្រឿងសក្ការៈបូជាអុជទៀនធូបតំទាប់ជាកិត្តិស័ព្ទកិត្តិយសបុប្ផទាំងបរិវេណ ។ បណ្ដាស្ត្រទាំងនោះដំរាបបុប្ផថា សុំឲ្យលោកតាំងទៀតពីទុកជាចៅហ្វាយស្រុកឈើជីរចុះ ។ បុប្ផតបថា គ្រានេះទៀតពីមានបំណាច់នឹងរាជការផែនដីច្រើនណាស់ យើងនឹងនាំខ្លួនចូលទៅក្រាបបង្គំគាល់ព្រះចៅហ្វៀនតេសិន បើទ្រង់ប្រោសព្រះរាជទានគុណបំណាច់ស្រេចហើយ ទើបនឹងវិលត្រឡប់មកឈរវែងត្រូតទៅ ។ បុប្ផក៏ចាត់ទាហានឲ្យនៅព្យាបាលករិយាបុត្រទៀតពីនៅក្នុងស្រុកឈើជីរនោះ ។

រួចបុប្ផក៏នាំទៀតពីលើកកងទ័ពត្រឡប់ចូលទៅក្រុងហ្វូតោ កាលទៅដល់ហើយ ក៏ចូលទៅក្រាបបង្គំគាល់ព្រះចៅហ្វៀនតេ ហើយក្រាបទូលថា គ្រានេះទៀតពីធ្វើរាជការមានសេចក្ដីគាប់ប្រសើរជាច្រើនណាស់ ៗ ព្រះចៅហ្វៀនតេ ទ្រង់ព្រះសណ្ដាប់ក៏មានព្រះទ័យសោមនស្សត្រេកអរ

ត្រាស់ឲ្យហៅឡៀវពីចូលទៅគាល់ហើយត្រាស់សួរថា អ្នកឯងជាបុត្រអ្នកឯណា ? ។ ឡៀវពីក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំជាបុត្រឡៀវហេងបិតាទូលព្រះបង្គំជាខ្ញុំជាពូជព្រះរាជវង្សព្រះចៅហៅគេងតេ ។ ព្រះចៅហៀនតេទ្រង់សណ្ដាប់ ក៏ត្រាស់បង្គាប់អាល័ក្សឲ្យយកពង្សាវតារមកទតរកតាមលំដាប់ក្សត្រតៗមកក៏ឃើញថា ឡៀវពីជាមារបស់ព្រះអង្គ ហើយទ្រង់តាំងឡៀវពីជាទីឃីតេងហោ គឺសេនាបតីធំខាងក្រមរាំង ។ អំណើះតមកព្រះចៅហៀនតេទ្រង់រកបានឡៀវពីហៅមា ។ បូងទឹងឡៀវពីក៏ថ្វាយបង្គំលាថយទៅទីលំនៅរៀងខ្លួន ។

ស៊ុនហុកចូលទៅជុំរកបូងថា ឥឡូវនេះព្រះចៅហៀនតេទ្រង់រកបានឡៀវពីថាជាពូជព្រះរាជវង្ស អំណើះតទៅគង់តែឡៀវពីនឹងគិតប្រទូសរ៉ាយដល់លោកជាប្រាកដ ។ បូងតបថា ដែលព្រះចៅហៀនតេរកបានឡៀវពីថាជាពូជព្រះរាជវង្សនោះមិនជាអ្វីទេ ព្រោះកិច្ចការរាជការទាំងពួងជាកម្មសិទ្ធិនៅលើយើងទាំងអស់ ឧបមាដូចពងមាន់នៅកងកណ្ដាប់ដៃយើង ទោះបីឡៀវពីនឹងប្រទូសរ៉ាយដល់យើងៗ ក៏មិនត្រូវញញើតសោះ សព្វថ្ងៃនេះយើងនៅបារម្ភក្រែងតែអៀវពីវ ដែលជាប្អូននឹងអ៊ួនសៀវ, អ៊ួនស៊ុតប៉ុណ្ណោះ ក្រែងរកមកធ្វើកលសឹកក្នុងទីក្រុង ព្រោះអ៊ួនសៀវនឹងអ៊ួនស៊ុតនៅមានកម្លាំងច្រើន ។ ស៊ុនហុកស្ដាប់យល់ត្រូវ ។

បូងទើបប្រើឧបាយកល ឲ្យបក្សពួករបស់ខ្លួនទៅលបស៊ើបស្ដាប់ថាអៀវពីវធ្វើសំបុត្រសំងាត់ទៅដល់អ៊ួនស៊ុតថា ឲ្យអ៊ួនស៊ុតលើកទ័ពមកវាយ

ស្រុកហ៊ូគោ អៀវតីវទីងទទួលធ្វើកលសឹកវានក្នុង ។ ចូឆូស៊ើបដឹងការ ប្រាកដក៏បង្គាប់ឲ្យចាប់ខ្លួនអៀវតីវដាក់គុកទុក ហើយឲ្យមានថងសារស្រេច សេចក្ដីធ្វើទោស ។ ខុងយុងដឹងការណ៍ក៏ចូលទៅជួបនឹងចូឆូហើយជំរាប ថា អៀវតីវធ្វើរាជការជានាម៉ឺនត ៗ ពីជីតាទឹងបិតារាបមកដល់ខ្លួន អៀវតីវនេះៗ មិនដែលធ្វើសេចក្ដីប្រទូស្តរ៉ាយដល់អ្នកឯណាសោះ ដែល លោកជឿស្ដាប់ពាក្យមនុស្សញុះញង់ មិនពិចារណាឲ្យឃើញវៀចនឹង ត្រង់សិននោះមិនគួរសោះ ហេតុនេះខ្ញុំបាទសុំឲ្យលោកពិចារណាតាម យុត្តិធម៌សិន ។ ចូឆូតបថា ការណ៍នេះជាព្រះរាជតម្រាស់ព្រះចៅ ហៀនតេ មិនមែនយើងធ្វើតាមអំពើចិត្តទេ ។

ខុងយុំងថា មហាឧបរាជជាអធិបតីសំរេចរាជការក្នុងព្រះនគរ ទោះ បីព្រះរាជតម្រាស់ព្រះចៅហៀនតេត្រាស់ឲ្យធ្វើយ៉ាងណា ក៏ត្រូវតែលោក ពិចារណាឲ្យឃើញខុសត្រូវសិន ។ ចូឆូបានឮដូច្នោះក៏មានសេចក្ដី ខ្មាស់ណាស់ ទើបឲ្យដោះលែងអៀវតីវចេញពីក្នុងគុក តែឲ្យហូតងារពី តំណែងមន្ត្រីរាជការ ។ អៀវសានជានាម៉ឺនរាជការព្រះចៅហៀនតេ ដឹងសេចក្ដីដូច្នោះ ក៏ធ្វើរឿងរ៉ាវក្រាបបង្គំទូលព្រះចៅហៀនតេឲ្យទ្រង់ ជ្រាបថា ចូឆូធ្វើការអែបបង្ខំព្រះតម្រាស់យកខ្លួនអៀវតីវទៅដាក់គុកហើយ ហូតងារចេញពីរាជការ ។ ព្រះចៅហៀនតេជ្រាបហើយក៏មិនត្រាស់ ថាប្រការម្ដេច ។ ចូឆូដឹងដូច្នោះ ក៏ប្រើទាហានទៅចាប់ខ្លួនអៀវសាន

យកទៅប្រហារជីវិតបង់ ៗ តាំងពីនោះរៀងមក នាហ្មឺនធំតូចនៅក្នុងក្រុងហ្វូគោ ក៏កោតខ្លាចបូឆូជាខ្លាំងណាស់ ៗ

ធៀយ៉ុកទីប្រឹក្សាចូលទៅនិយាយនឹងបូឆូថា ឥឡូវនេះបណ្ដានាហ្មឺនតូចធំនិយមកោតខ្លាចអំណាចមហាឧបរាជទាំងអស់ហើយ ហេតុម្ដេចមហាឧបរាជមិនគិតយករាជសម្បត្តិតែម្ដងទៅ នឹងបង្អង់ទុកនៅចាំដល់ណាទៅទៀត ៗ បូឆូតបថា ' វេលានេះនៅមាននាហ្មឺនមុខមន្ត្រីដែលព្រះចៅហៀនតេ ទុកព្រះទ័យច្រើនណាស់ បើយើងនឹងធ្វើការវូតវះមិនបានសម្រេចដូចចិត្តនៅឡើយ បើដូច្នេះត្រូវយើងរិះគិតអញ្ជើញស្ដេចព្រះចៅហៀនតេទៅប្រពាតព្រៃមើលកល់ការសិន" និយាយហើយក៏ចាត់ចែងគ្រឿងប្រដាប់សម្រាប់ប្រពាតព្រៃទុកព្រមស្រេច ក៏ចូលទៅក្រាបទូលអញ្ជើញស្ដេចចេញទៅប្រពាតព្រៃជាកំសាន្ត ៗ

ព្រះចៅហៀនតេត្រាស់ថា នឹងទៅលេងព្រៃនោះមិនត្រូវព្រយការនឹងសេនាទាហានទេ ព្រោះគ្មានផលប្រយោជន៍អ្វីសោះឡើយ ៗ បូឆូក្រាបទូលថា ប្រវេណីនៃព្រះមហាក្សត្រពីបូរាណ ស្ដេចចេញទៅប្រពាតព្រៃសំសាន្តក្នុង ១ ឆ្នាំ ៤ ដង ត្រូវល្បងថ្វីដៃសេនាទាហានផង ឥឡូវក្នុងព្រះរាជអាណាខែត្រក៏មិនទាន់រាបទាបជាប្រក្រតី សូមអញ្ជើញស្ដេចចេញទៅប្រពាតព្រៃ នឹងបានទតខ្ញុំរាជការទាំងពួងល្បងថ្វីដៃបាញ់ធ្នូ ៗ ព្រះចៅហៀនតេទ្រង់ព្រះសណ្ដាប់ក៏មិនអាចនឹងទទឹងទាស់បូឆូបាន បូឆូ

ក៏បានប្រមូលពលទាហាន ១០ ម៉ឺន ព្រមដោយគ្រឿងសស្ត្រាវុធ ព្រះចៅហៀនគេក៏យាងគង់លើទីនាំងអស្សតរ បណ្ដានាហ្មឺនមុខមន្ត្រីទីងឡេពី, គួនអ៊ូ, គៀវហ៊ុយ ក៏ជិះសេះហែហមអមស្ដេចចេញទៅ ។ ឯចូឆូក៏ធ្វើឫកពាដូចជាស្ដេច ជិះសេះអែបព្រះទីនាំងមិនបានកោតក្រែងព្រះបស្ដា លុះស្ដេចយាងទៅដល់ជាយព្រៃព្រឹក្សមានរល្វើ៍ហោះមួយអន្ទើកឲ្យឈប់គង់ទីព ។ នាហ្មឺនទីងសេនាទាំងពួង ក៏លើកគ្នាដេញហ្វូងសត្វកៀរប្រមូលចូលទៅត្រង់ប្រកកំមុខព្រះភ័ក្ត្រ ។ ព្រះចៅហៀនគេក៏ទ្រង់ត្រាស់ទីងឡេពីថា យើងចង់ឃើញថ្វីដៃមាបាញ់សត្វនោះល្អងមើល ។ ឡេពីទទួលព្រះរាជឱង្ការហើយក៏ឡើងសេះបាញ់ធ្នូទៅត្រូវមាំង ១ ដួលបុះនៅទីនោះ ។

ព្រះចៅហៀនគេក៏ទ្រង់ធ្នូបាញ់ប្រើសមិនត្រូវ ទើបត្រាស់ទីងចូឆូថា អ្នកចូរបាញ់ប្រើសនោះឲ្យបាន ។ ចូឆូទូលថា បើព្រះអង្គទីងចង់ទតថ្វីដៃទូលព្រះបង្គំជាខ្ញុំ សុំព្រះករុណាព្រះរាជទានធ្នូព្រះសែងមកបុះទូលព្រះបង្គំជាខ្ញុំទីងបាញ់ថ្វាយទត ។ ព្រះចៅហៀនគេក៏ហុចព្រះសែងកៅទ័ណ្ឌទ្រង់ឲ្យទៅចូឆូ ៗ ទទួលហើយក៏លើកឡើងបាញ់ទៅ ត្រូវប្រើសនោះដួលបុះមួយរំពេច ។ នាហ្មឺនទាំងពួងដែលនៅពីចម្ងាយឃើញព្រះសែងកៅទ័ណ្ឌចំព័ន្ធរូបមាស ត្រូវប្រើសដួលដូច្នោះ ក៏ស្មានថា "ព្រះចៅហៀនគេទ្រង់ថ្វីងព្រះអង្គឯង" ទាំងអស់គ្នាក៏ចូលមកក្រាប

ថ្វាយបង្គំចំពោះព្រះភ័ក្ត្រ ៗ ចូឆូឃើញដូច្នោះក៏កើតសោមនស្សប្រីតាបរសេះកាត់មុខព្រះភ័ក្ត្រាចេញទៅហើយស្រែកថា ខ្លួនយើងបាញ់ត្រូវប្រើសនេះ ៗ នាហ្មឺនទឹងសេនាពាហានទាំងពួង ឃើញចូឆូធ្វើកិរិយាមើលងាយព្រះចេស្តាដូច្នោះ ក៏ភ្ញាក់ស្មារតីស្ងាំងកាំងទាំងអស់គ្នា ៗ

គួនអ៊ូឃើញចូឆូធ្វើអាកប្បកិរិយាដូច្នោះក៏ទឹកខឹងណាស់ បរសេះចូលទៅលើកដាវឡើងទឹងកាប់ចូឆូ ហើយក្រឡេកមកមើលមុខឡៅពី ៗ ក៏ញាក់ភ្នែកបញ្ឈប់ហើយគ្រវីក្បាល ៗ គួនអ៊ូក៏ឈប់ថយចេញ ៗ ឡៅពីនិយាយថា ចុះដៃមហាឧបរាជបាញ់ធ្លុះនេះទឹងរកអ្នកឯណាស្មើមិនបានទេ ៗ ចូឆូក្លែងតបថា "ចុះដៃយើងជាប្រមាណយ៉ាងសមគួរប៉ុណ្ណោះ" ហើយត្រឡប់មុខមកគំនាប់ព្រះចៅហៀនតេរួចក្រាបទូលថា ដែលទូលព្រះបង្គំបាញ់ទៅត្រូវប្រើសនោះ ព្រោះព្រះសែងកៅទ័ណ្ឌទឹងព្រះបារមីរបស់ព្រះអង្គជួយទ្រទ្រង់ ៗ ព្រះចៅហៀនតេទ្រង់មិនជ្រាបឧបាយកលចូឆូក៏នាំនាហ្មឺនមុខមន្ត្រីក្រសាលដេញសត្វកំសាន្តព្រះទ័យ លុះពេលរសៀលហើយក៏ស្តេចត្រឡប់ចូលក្នុងព្រះបរមរាជវាំងវិញ ៗ ចូឆូក៏យកព្រះសែងកៅទ័ណ្ឌទុកជាកម្មសិទ្ធិមិនបានថ្វាយទៅវិញ ៗ ឯនាហ្មឺនមុខមន្ត្រីក៏ត្រឡប់ទៅទីលំនៅរៀងខ្លួន ៗ

គួនអ៊ូនិយាយទឹងឡៅពីថា ចូឆូធ្វើកិរិយាមើលងាយព្រះចេស្តាខ្ញុំប៉ងទឹងសម្លាប់ចេញ ហេតុៈម្តេចបានជាបង្ឃាត់ខ្ញុំ? ៗ ឡៅពី

តបថា ព្រះចៅហៀនតេនឹងខ្លួនបងវេលានោះនៅក្នុងចំណោមទាហានចូចូ បើប្អូនសម្លាប់ចូចូហើយ ទាហានគេក៏សម្លាប់បងវិញ ហើយនឹងធ្វើអន្តរាយដល់ព្រះចៅហៀនតេផង ព្រោះហេតុនេះបានជាបងហាមឃាត់ ៗ

ខណៈនោះ ព្រះចៅហៀនតេយាងចូលទៅរកព្រះនាងហុកហៅជាអគ្គមហេសី ហើយត្រាស់ប្រាប់ពីរឿងចេញទៅប្រពាតព្រៃ ចូចូធ្វើកិរិយាមើលងាយកណ្ដាលទីប្រជុំ ឲ្យព្រះអគ្គមហេសីស្ដាប់គ្រប់ប្រការ ទ្រង់ត្រាស់ថាខ្លួនយើងបានសោយរាជសម្បត្តិនេះ មានតែសេចក្ដីព្រួយរំខានក្នុងចិត្តឥតស្រាកស្រាន្ត កាលគ្រាតាំងតុះក៏ធ្វើអាក្រក់នឹងយើងច្រើន កាលគ្រាលីឈុយគុយគីក៏ធ្វើអន្តរាយដល់យើងផ្សេងៗ ឥឡូវយើងគិតថា ចូចូនឹងជួយទំនុកបំរុងផែនដី ក៏ត្រឡប់មកធ្វើអប្រិយអាក្រក់ដល់យើងទៀត ជីវិតរបស់យើងនឹងនាងនេះ មិនដឹងជាមានសេចក្ដីស្លាប់មកដល់ថ្ងៃណាទេ" ៗ ព្រះចៅហៀនតេទ្រង់ពណ៌នារួចហើយក៏ទ្រង់ព្រះកន្សែងពិលាប ៗ ព្រះអគ្គមហេសីបានទ្រង់ជ្រាបតាមក្រសែព្រះរាជឱង្ការព្រះស្វាមី ក៏ទ្រង់ព្រះកន្សែងថ្លែងថា នាហ្មឺនមុខមន្ត្រីធំតូចទាំងប៉ុន្មានសុទ្ធតែបានស៊ីបៀវត្សរ៍គ្រប់គ្នា ម្ដេចក៏ចេះតែមើលបំណាំមិនជួយទំនុបំរុងផែនដី លះបង់មេត្រីទុកឲ្យព្រះអង្គសោយទុក្ខលំបាកដូច្នេះ ក៏ជាកេណ្ឌកម្មសម្រាប់ព្រះអង្គនឹងខ្ញុំម្ចាស់ ៗ

ពេលនោះ ទទួលហុកអ៊ួនជាបិតាព្រះនាងហុកហៅចូលទៅគាល់ខាងក្នុង ឃើញព្រះចៅហៀនតេទ្រង់ព្រះកន្សែងក៏ទូលសួរថា ព្រះ

អង្គទ្រង់ត្រាស់ព្រះហ្ឫទ័យពីការអ្វី ឬនឹងនរណា ? ។ ព្រះចៅហៀនគេក៏អធិប្បាយរ៉ាយរឿង ដែលចូច្ចធ្វើល្មើសមើលងាយប្រមាថឲ្យហុកអ៊ួនស្ដាប់គ្រប់ប្រការ ។ ហុកអ៊ួនក៏ទូលថា កាលស្ដេចចេញទៅប្រពាតព្រៃនោះទូលព្រះបង្គំជាខ្ញុំក៏បានឃើញជាក់ច្បាស់ទាំងអស់ហើយ តែមិនដឹងធ្វើប្រការម្ដេច សូម្បីនាហ្ម៉ឺនមុខមន្ត្រីទាំងពួងក៏មិនមានឈឺចិត្តក្ដៅជួសព្រះអង្គ ទូលព្រះបង្គំឃើញតែតាំងស៊ុនជាព្រះរាជវង្សនឹងជួយគិតអានគិតកំចាត់ចូច្ចចេញបាន ។

ព្រះចៅហៀនគេត្រាស់ថា ការទាំងនេះត្រូវនឹងរកតាំងស៊ុនចូលមកគាល់នឹងបានពិគ្រោះប្រឹក្សា ឬនឹងគិតប្រការម្ដេច ? ។ ហុកអ៊ួនទូលថា សព្វថ្ងៃនេះចូច្ចនឹងបានទុកចិត្តដល់ព្រះអង្គក៏ទេ វាមានប្រើមនុស្សស្រីជាទំនុកទុកចិត្តឲ្យចូលមកចាំស្ដាប់ការល្អអាក្រក់ ក្នុងព្រះបរមរាជវាំងជានិច្ច ដែលទ្រង់នឹងឲ្យហៅតាំងស៊ុនចូលមកក្រាបបង្គំគាល់នោះ ខ្លាចដំណឹងទៅដល់ចូច្ច ការដែលគិតទុកក៏នឹងខូចអសារទៅ សូមឲ្យព្រះអង្គទ្រង់ព្រះអក្សរលាក់ទុកក្នុងស្រទ័ពអាវឲ្យកំបាំង រួចទ្រង់ឲ្យហៅតាំងស៊ុនចូលមកគាល់រួចយកអាវនោះព្រះរាជទានឲ្យតាំងស៊ុន ហើយទ្រង់ប្រាប់តាំងស៊ុនថា បើបានទៅដល់ផ្ទះហើយឲ្យយកព្រះអក្សរចេញមកមើល ឃើញថាចូច្ចនឹងមិនបានដឹងសេចក្ដីកំបាំងនោះឡើយ ។ ព្រះចៅហៀនគេក៏ទ្រង់យល់ឃើញត្រូវ ហុកអ៊ួនក៏លាចេញទៅ ។

ព្រះចៅហៀនគេយកព្រះសែងពាក់ម្រាមព្រះហស្តឲ្យព្រះលោហិតហូរចេញមក ហើយយកពិតជ្រលក់សរសេរលើផែនព្រែសតាមព្រះរាជដំរិះ ហើយបង្គាប់ព្រះអគ្គមហេសីលាក់សឹកទុកក្នុងស្រទាប់ជាយអាវ ហើយទ្រង់ឲ្យហៅខុនតាំងស៊ុនចូលទៅគាល់ មានព្រះរាជឱង្ការត្រាស់ថា "កាលពីយប់មិញ យើងនឹងព្រះអគ្គមហេសីនឹកដល់អ្នក កាលគ្រានាំយើងរត់ពីលើឈុយនុយតីទៅនោះ សេចក្តីគាប់ប្រសើររបស់អ្នកក៏មានលើយើងច្រើនណាស់ ហេតុនេះយើងឲ្យអាវនេះដល់អ្នកជាបំណាច់យ៉ាងតិចតួច" ហើយទ្រង់ឱនខ្សឹបថា បើទៅដល់ផ្ទះវិញឲ្យយកសំបុត្រក្នុងស្រទាប់អាវមើល បើបានឃើញអាការៈទុក្ខក្តៅរបស់យើងយ៉ាងណា ចូរប្រញាប់គិតការនោះឲ្យសម្រេច សុំកុំឲ្យអ្នកឯណាដឹងដល់យល់សេចក្តី ៗ តាំងស៊ុនក៏ទទួលយកអាវដែលទ្រង់ព្រះរាជទាន ហើយក៏លើកពាក់បំពោះព្រះភ័ក្ត្រ រួចក៏ក្រាបថ្វាយបង្គំលាចេញតាមទ្វារព្រះបរមរាជវាំងខាងក្នុងនឹងតម្រង់ទៅផ្ទះ ៗ

(មានត)

# ណាលៈ និង ទមយន្តី

រឿងព្រេងប្រទេសឥណ្ឌា

## អ្នកស្រីត្រឹង-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

ពេលប្រជុំមហាសន្និបាតក៏កាន់តែខិតចូលមកជិតណាស់ហើយ, នៅខណៈនោះ ឫស្សីក្នុងទេវពិភព ឈ្មោះនារទៈ (Narada) និងបវ៌តៈ (Parvata) ទាំងពីរអង្គឡើងទៅគាល់សម្ដេចព្រះឥន្ទ្រាធិរាជ, ដល់ហើយព្រះឥន្ទ្រនិងឥសីក៏ធ្វើគារវកិច្ចចំពោះគ្នាទៅវិញទៅមក ៗ បន្ទាប់មកព្រះឥន្ទ្រាធិរាជក៏មានព្រះបន្ទូលសួរឥសីថា: "ម្នាលឥសីបណ្ឌិត! តើអ្នកអាចប្រាប់យើងបានទេ ថាហេតុអ្វីបានជាយើងលែងឮនូវសំណូរនៃស្ដេចទាំងឡាយនៅលើផែនដី សូត្រធម៌នមស្សការយើង?" ឫសីនារទៈក្រដូវប្ដោះញញឹមធ្វើព្រងើយ ហើយឆ្លើយតបថា "ឱព្រះដ៏មានបុណ្យប្រសើរអើយ! ទូលបង្គំដឹងហេតុដែលព្រះដ៏ជាធំលែងឮធម៌នមស្សការនៃស្ដេចទាំងឡាយនោះ ៗ ស្ដេចត្រង់រាជ្យនៅប្រទេសវិទភៈ មានព្រះរាជបុត្រីមួយព្រះអង្គទ្រង់នាមទមយន្តី ព្រះនាងល្អឆើតលើសក្សត្រីផងក្នុងលោក ៗ ព្រះនាងនឹងរើសរកស្វាមីដោយព្រះអង្គឯង ហើយស្ដេចទាំងប៉ុន្មាននាំគ្នាទៅប្រជុំក្នុងរាជសន្និបាត ដោយមានព្រះទ័យស្មើរតែរលាករលួយ មិនដឹងគិតធ្វើម្ដេចនឹងបាន

បំពេញព្រះហឫទ័យព្រះនាង" ។ ព្រះឥន្ទ្រនិងព្រះអគ្និ (Agni) ព្រមទាំងទេវតាឯទៀតស្ដាប់ហើយ ។ លុះឫសីថ្លែងសេចក្ដីចប់កាលណា ពួកទេវតាមើលមុខគ្នាទៅវិញទៅមក ។ ព្រះអគ្និផ្ដើមមានបន្ទូលថា: "នារទអ្នកឯងថាព្រះនាងទមយន្តីល្អផុតស្រីទាំងពួងឬ?" ។ ឥសីនារទ;ឆ្លើយថា: "មនុស្សទាំងអស់ក៏ថាដូច្នេះដែរ" ។ ព្រះឥន្ទ្រាធិរាជក៏ងាកមក មានបន្ទូលនឹងទេវតាឯទៀតថា: "តើយើងនឹងទៅដណ្ដើមយកស្រីដែលល្អឯកអំពីពួកស្ដេចពិភពលោកដែរឬទេ?" ។ ព្រះអគ្និដែលមានសន្ដានចិត្តពុះពោរដោយចំណង់ខ្លាំងក៏ឆ្លើយតបភ្លាមថា: "ទៅ! ទៅ! យើងនាំគ្នាចុះទៅកាន់ប្រទេសព្រះបាទភិម: ឲ្យព្រះនាងទមយន្តី រើសយកស្វាមីជាព្រះអាទិទេពវិញ" ។ គ្រានោះព្រះឥន្ទ្រាធិរាជ ព្រះអគ្និនិងទេវតាឯទៀតជាច្រើន ហោះចុះមកកាន់ប្រទេសព្រះបាទភិម: ព្រមទាំងក្បួនហែហមអមព្រះអង្គជាច្រើនឥតគណនា ។

វគ្គទី ៧

ព្រះបាទនល: ក៏បានទទួលដំណឹងជាទីគាប់ព្រះហឫទ័យនោះពីពជទូតដែរ ពិតមែនតែទ្រង់ពុំដែលយល់ព្រះភក្ត្រព្រះនាងទមយន្តី, ប៉ុន្តែទ្រង់មានព្រះហឫទ័យប្រតិព័ទ្ធចំពោះព្រះនាង លើសលែងអ្វីនៅក្នុងលោកទាំងអស់ ។ ព្រះអង្គទ្រង់យាត្រាដំរង់ទៅប្រទេសវិទភៈ ដោយមានព្រះហឫទ័យស្រាលស្រឡះ ។

ពួកទេវតាព្រមទាំងព្រះអគ្គី ក៏ឡើងទៅឃើញស្គាល់ច្បាស់ជាព្រះបាទនាលៈ ហើយគេប្រាប់គ្នាថា: "ហ្នឹងហើយព្រះបាទនាលៈ ដែលទៅកាន់ប្រទេសព្រះបាទភិមៈដែរ ក្នុងចំណោមបុរសដែលនៅក្នុងលោកគ្មានអ្នកណាមួយល្អដូចព្រះបាទនាលៈទេ ចុះអ្នកណាអាចដឹងបានថាព្រះនាងទមយន្តី ពេញព្រះទ័យនឹងក្សត្រនេះជាជាងពួកអាទិទេពទាំងអស់ឬ? ប៉ុន្តែព្រះបាទនាលៈជាស្តេចគោរពសាសនា ត្រូវយើងកុំលាក់បំណងរបស់យើងឡើយ យើងត្រូវប្រើទ្រង់ជាអ្នកបំរើយើងវិញ" ។ ព្រះឥន្ទ្រាធិរាជតបថា: "ធ្វើតាមតែអ្នកឯងគិតឃើញចុះ" ។ ក្នុងខណៈនោះ ពួកព្រះអាទិទេពនាំគ្នាបញ្ឈប់នូវរាជរថនៃព្រះបាទនាលៈ ហើយព្រះអគ្គីពោលថា: "ម្នាលនាលៈ ឯងជាកំពូលនៃមនុស្សលោក ហើយឯងតែងតែធ្វើភក្តីភាពចំពោះអាទិទេពជានិរន្តរ៍ ។ ចូរឯងដឹងថា អ្នកដែលនិយាយទៅកាន់ឯងនេះ ជាព្រះអគ្គី នៅក្បែរខាងខ្ញុំនេះជាព្រះឥន្ទ្រាធិរាជ យើងទាំងអស់គ្នាជាអាទិទេព" ។ ព្រះបាទនាលៈ ក៏លើកកបង្គំហើយពោលថា: "ខ្ញុំសូមនមស្សការគោរពព្រះអាទិទេពទាំងអស់" ។ ព្រះអគ្គីញញឹមហើយតបថា: "ល្អហើយ ប៉ុន្តែឯងត្រូវបំពេញកិច្ចមួយឲ្យយើង ឯងធ្វើជាអ្នកនាំសារឲ្យយើង" ។

– "ទោះជាទូលបង្គំមានកិច្ចប្រញាប់ចំពោះការធ្វើដំណើរនេះ ឲ្យដល់នូវគោលបំណងយ៉ាងណា ក៏ទូលបង្គំនៅតែស្តាប់បង្គាប់អាទិទេពដែរ តើទូលព្រះបង្គំត្រូវនាំសារអ្វី? ហើយនឹងត្រូវទៅឯប្រទេសណា?" ។

- ព្រះឥន្ទ្រាធិរាជមានបន្ទូលថា: "យើងមានចិត្តសោមនស្សនឹងឯងណាស់ អមតកៈបុរសមានសេចក្ដីស្នេហាចំពោះមតកៈនារី ។ យើងបានឮកិត្តិសព្ទនៃព្រះនាងទមយន្តីល្បីល្បាញក្នុងពិភពលោក គេនឹងបើកសន្និបាតប្រជុំនៅកន្លែងដែលនាងត្រូវរើសស្វាមីដោយខ្លួនឯង ហើយស្វាមីនៃនាងត្រូវតែជាអាទិទេព" ។ ព្រះបាទនលៈមានព្រះភក្ត្រស្ងាំងមួយរំពេច ។ ព្រះឥន្ទ្រាធិរាជមានព្រះបន្ទូលតទៅទៀតថា "ចូរឯងទៅរកក្សត្រីទមយន្តី ហើយទូលព្រះនាងថា: យើងប្រុងនឹងដំកើងកិត្តិយសនៃព្រះនាងឲ្យស្មើនឹងអាទិទេព ព្រះនាងមិនបាច់ចាំរើសយកមហាពជណាមួយទេ ។ ចូរឯងនិយាយដូចម្ដេចឲ្យខាងតែព្រះនាងស្គាល់ច្បាស់នូវករណីយកិច្ចរបស់ព្រះនាង" ។

ព្រះបាទនលៈស្ទើរតែនឹងស្លុតបាត់ស្មារតី ហើយមានព្រះបន្ទូលទាំងភ័យថា: "ឱព្រះអាទិទេព! ទ្រង់ចង់ធ្វើឲ្យទូលបង្គំកើតសេចក្ដីលំបាកឬ? ។ ព្រះគុណមិនមែនមិនជ្រាបថា ទូលបង្គំនឹងទៅកន្លែងនោះទេ ព្រះគុណមិនមែនមិនជ្រាបថា ទូលបង្គំស្រឡាញ់ព្រះនាងទមយន្តីទេ បើដូច្នេះតើទូលបង្គំនឹងធ្វើជាអ្នកនាំសាររម្ដេចបាន?" ថាហើយព្រះអង្គក៏លើកកបង្គំហើយពោលតទៅទៀតថា: "ឱព្រះអាទិទេពដ៏ប្រសើរអើយ! ទូលបង្គំសូមអង្វរកុំឲ្យទ្រង់ប្រើទូលបង្គំទៅកន្លែងនោះ, តើទូល

បង្គំនឹងអាចទៅប្រាប់ស្រីដែលទូលបង្គំស្រឡាញ់ថា ឲ្យទៅធ្វើប្រពន្ធអ្នកដទៃទៀតម្ដេចបាន?" ។

ព្រះឥន្ទ្រាធិរាជឆ្លើយថា:

- "នៃនាល:! ឯងបានទទួលសន្យានឹងយើងហើយ" ។

- ឱព្រះអាទិទេព! ទូលបង្គំកើតទុក្ខពន់ពេកណាស់ សូមទ្រង់ប្រោសប្រណី ។

- នាល:ឯង បានទទួលកិច្ចសន្យានឹងយើងហើយ ឯងបានព្រមទទួលស្ដាប់បង្គាប់យើង បើដូច្នេះ ឯងត្រូវធ្វើតាមយើង ។

ព្រះបាទនាល: ទ្រង់សំឡឹងព្រះឥន្ទ្រាធិរាជនឹងព្រះអគ្គី ដោយមានទឹកព្រះនេត្រ ដោរដលរហាម ហើយក៏ពោលតទៅទៀតថា: "ប្រទេសព្រះបាទភិម: មានមនុស្សយាមមាំទាំណាស់ តើទូលបង្គំនឹងចូលទៅដូចម្ដេចបាន?" ។

ព្រះឥន្ទ្រាធិរាជតបថា "ចូរឯងកុំបារម្ភ ទ្វារទាំងប៉ុន្មាននឹងបើកឲ្យឯងស្រាប់ៗ ស្ដាប់តែបង្គាប់យើងចុះ" ។

ព្រះបាទនាល: ដែលគោរពទន់ទៅដោយសេចក្ដីទុក្ខ ក៏ឆ្លើយដោយសំឡេងខ្សាប់ៗទៅវិញថា: "ទូលបង្គំព្រមស្ដាប់បង្គាប់" ។

វគ្គទី ៨

ព្រះបាទនាល: ក៏ធ្វើដំណើរទៅទៀត ប៉ុន្តែទ្រង់ដាក់ព្រះនេត្រចុះ ដោយមានព្រះហឫទ័យព្រួយខ្លាំងពេក ទោះជាទ្រង់មានចិត្តក្លាហាន

យ៉ាងណាក៏ទ្រង់មិនអាចនឹងទប់ទឹកព្រះនេត្របាន ។ ជួនកាលទ្រង់ភ្លាត់ព្រះអង្គដល់ទៅទ្រង់ព្រះកន្សែងយ៉ាងខ្លាំងផង ។ ក្រោយមកទ្រង់ក៏បានដល់ទៅប្រទេសព្រះបាទភិម: ទ្រង់ក៏យាងចូលទៅ ពួកឆ្មាំទ្វារគ្មានឃាត់ទ្រង់សោះ ហើយហាក់ដូចជាគ្មានទាំងឃើញទ្រង់ផង ទ្វារទាំងប៉ុន្មានក៏បើកថ្វាយទ្រង់ឯង មានបន្ទប់ខ្លះទំនេរស្អាត មានបន្ទប់ខ្លះទៀតមានពួកចៅចមនឹងអ្នកបំរើអង្គុយត្រៀបត្រា ព្រះបាទនល:ទ្រង់យាងកាត់បន្ទប់ទាំងនោះដោយគ្មានអ្នកណានិយាយរកទ្រង់ ១ ម៉ាត់សោះ ទ្រង់ក៏នឹកថាព្រះអាទិទេពបានបំបាំងខ្លួនអញកុំឲ្យមើលឃើញ ។ ព្រះក៏ជាចេញផុតពីទ្វារមួយក្រោយបង្អស់ ហើយទ្រង់យាងចូលទៅក្នុងព្រះរាជឧទ្យាន ។ ព្រះអង្គទ្រង់យាងក្រសាល បន្តិចស្រាប់តែទ្រង់ក្រឡេកឃើញនៅទីគុម្ពជាមួយ ស្រីៗលេងសើចរបល់ ។ ទ្រង់ក៏ត្រាច់សំដៅទៅហ្វូងស្រីៗ ដែលទ្រង់ទតស្គាល់ជាព្រះនាងទមយន្តីនៅជាកណ្ដាល ។ ព្រះអង្គទ្រង់ព្រះកន្សែងដោយមានសេចក្ដីស្នេហា នឹងសេចក្ដីត្រេកអរផង ដោយនឹកឃើញកិច្ចសន្យាជាមួយនឹងព្រះឥន្ទ្រផង ហើយនឹងនឹកព្រួយជាខ្លាំងផង ។ ព្រះនាងទមយន្តីក្រឡេកឃើញស្គាល់ជាព្រះបាទនល: ពីព្រោះព្រះអាទិទេពលែងបំបាំងទៀតហើយ ។ ព្រះនាងភ្លាត់សំរែកដោយសេចក្ដីអរពេក ប៉ុន្តែព្រះនាងមិនរត់ទេ ទ្រង់ឈានពីរបីជំហានទៅជិតព្រះអង្គ ហើយទ្រង់ថយមកវិញ ព្រោះព្រះនាងទ្រង់ញញើត ទ្រង់មិន

ហានមានព្រះបន្ទូលទៅកាន់ព្រះអង្គមុនទេ ប៉ុន្តែរមព្រះឱស្ឋព្រះនាងហើប ឡើងឯងយ៉ាងប្រិមប្រិយស់ ។ ព្រះបាទនាលៈលែងទ្រង់ព្រះកន្សែងសោះ ព្រោះទ្រង់រំបរ្ក្រាបសេចក្តីទុក្ខរបស់ព្រះអង្គ ហើយទំជំរង់គោរពកិច្ច សន្យា ។ បន្ទាប់មកព្រះនាងទមយន្តីទំជំឡើងសេចក្តីក្លាហាន ហើយមានព្រះបន្ទូលសួរទៅព្រះកជាថា "ព្រះអង្គដែលមានរូបឆោមលោម ពណ៌គួរឲ្យចេតនា តើព្រះអង្គជាអ្វី? ស្តេចយាងមកពីប្រទេសណា? ព្រះនាមអ្វី?" ។ ព្រះបាទនាលៈត្រាស់តបថា: ឱព្រះនាងដ៏ល្អវិសេស! ខ្ញុំឈ្មោះនាលៈ ។

ព្រះនាងមានបន្ទូលដោយរីករាយថា "ខ្ញុំម្ចាស់ស្គាល់ហើយ ខ្ញុំម្ចាស់ នៅចាំតែព្រះអង្គទេតើ" ថាហើយព្រះនាងទះព្រះហស្តទ្រង់ព្រះសំរួល យ៉ាងវែង ដែលមានព្រះសូរសៀងដូចជាគេច្រៀង ។

ព្រះបាទនាលៈមានបន្ទូលតទៅទៀតដោយមានសំឡេងមាំថា: "ខ្ញុំជាអ្នកនាំសារនៃអាទិទេពទេ ។ ព្រះឥន្ទ្រាធិរាជ ព្រះអគ្គីនិងព្រះវរុណ (Varuna) ទាំងបីអង្គនេះចង់បានព្រះនាងធ្វើជាឯកអគ្គមហេសី ។ ព្រះនាងត្រូវរើសយកអាទិទេពណាមួយជាស្វាមីក្នុងអាទិទេពទាំងអស់នេះ សូមព្រះនាងបំពេញព្រះទ័យនៃអាទិទេពកុំខាន ឱ! ព្រះនាងដែលមានរូបឆោមធ្វើឲ្យខ្ញុំពិលក្នែក! ឥឡូវនេះ ខ្ញុំបានបំពេញកិច្ចខ្ញុំរួចហើយ" ។ ព្រះកជាក៏ទ្រង់យាងចេញត្រឡប់មកវិញ ព្រោះព្រះអង្គខ្លាចក្រែងនៅ

យូរទៅក្នាត់គំនិត ។ ប៉ុន្តែព្រះនាងឃាត់ព្រះអង្គថា: "ទេ! ទេ! កុំស្ដេចត្រឡប់ទៅវិញ" ព្រះនាងទ្រង់ញញឹម ហើយមានបន្ទូលតទៅទៀតថា: "ខ្ញុំម្ចាស់សុខចិត្តទទួលព្រះអង្គជាអ្នកនាំសារនៃសេចក្ដីស្នេហា ប៉ុន្តែព្រះអង្គត្រូវតាំងជាអ្នកនាំសាររបស់ព្រះអង្គឯងទៅវិញ ។ ខ្ញុំម្ចាស់មិនភ្លេចនូវសេចក្ដីពណ៌នារបស់ក្ងានព្រៃទេ ព្រះរាជសន្និបាតនេះកើតឡើងសម្រាប់តែព្រះអង្គប៉ុណ្ណោះ ។ សូមព្រះអង្គកាន់ភក្ដីភាពចំពោះខ្ញុំម្ចាស់ ដូចជាខ្ញុំម្ចាស់ប្រព្រឹត្តចំពោះទ្រង់ ។ សូមព្រះអង្គស្រឡាញ់ខ្ញុំម្ចាស់ ដូចជាខ្ញុំម្ចាស់ស្រឡាញ់ចំពោះទ្រង់" ។

ព្រះបាទនល: ឆ្លើយដោយរំជួលព្រះទ័យខ្លាំងថា: "តើនៅក្នុងចំណោមអាទិទេព ព្រះនាងនឹងអាចរើសយកមនុស្សជាស្វាមី បានដែរឬ?" ។

– បើព្រះអង្គបោះបង់ខ្ញុំម្ចាស់ៗនឹងស្លាប់ដោយថ្នាំពុល ដោយភ្លើង ឬដោយទឹក . . . ។ ខ្ញុំម្ចាស់មិនដឹងជាស្លាប់នឹងអ្វីទេ ប៉ុន្តែខ្ញុំម្ចាស់នឹងស្លាប់ពុំខាន ។

– សូមព្រះនាងកុំធ្វើឲ្យនាយកនៃពិភពលោកអាក់អន់ស្រពន់ព្រះទ័យ កុំឲ្យលោកតាមផ្ដន្ទាដោយព្រះក្រោធ ។ សូមព្រះនាងនឹកដល់សេចក្ដីស្រួល សេចក្ដីសប្បាយដែលព្រះនាងស្អប់ខ្ពើមសិន ។ ព្រះកេសានៃព្រះនាងនឹងភ្លឺរន្ទាលប្រាលម្អដោយផ្កាស្ថានសួគ៌ ព្រះនាងនឹងទ្រង់

សុទ្ធតែព្រះពស្ត្រដ៏មានរស្មីភ្លឺត្រចះ ។ ព្រះនាងទមយន្តី! សូមព្រះនាងទ្រង់ព្រះសណ្តាប់ខ្ញុំ : កុំព្រះនាងរត់ទៅរកនូវសេចក្តីវិនាសឡើយ ។

- ព្រះអង្គនាល: ខ្ញុំម្ចាស់នឹងទុនក្រាបគោរពចំពោះព្រះភក្ត្រព្រះអាទិទេព ហើយខ្ញុំម្ចាស់នឹងរើសយកព្រះអង្គជាស្វាមី ។

ព្រះបាទនាល: ទ្រង់ព្រះសណ្តាប់នូវបន្ទូលព្រះនាងហើយ ក៏មានព្រះអង្គញ័រចំប្រប់ដោយសេចក្តីស្នេហាដុតពេលព្រះអង្គ, ព្រះអង្គមានសេចក្តីសង្ឃឹមឡើងវិញ តើព្រះអង្គនឹងប្រមាថអាទិទេពឬ? ហើយទ្រង់បញ្ចេញសេចក្តីត្រេកអរថា: "តែប៉ុណ្ណះបានការណ៍ហើយ អាទិទេពនឹងមិនទោទប្រកាន់ដល់អញឡើយ ព្រោះអញគ្មានប្រព្រឹត្តក្បត់ចំពោះលោកទេ អញខំអត់ទ្រាំបាន ហើយចេះខំការពារលោកដោយគ្មានបណ្តោយចិត្តឲ្យទន់សោះ ។ អញបានធ្វើឲ្យនឹងចិត្តអញ ណ្ហើយព្រះនាងកុំមានបន្ទូលអ្វីទៀត, ឱព្រះនាងទមយន្តីជាធ្មេចិត្តតែមួយរបស់ខ្ញុំ! ប្អូននាងធ្វើតាមតែព្រះទ័យនាងចុះ" ។

ប៉ុន្តែ ព្រះនាងនៅតែឃាត់ស្តេចទៀតថា: "យើងទាំងពីរនាក់នឹងសប្បាយចិត្តដូចគ្នា ។ សូមទ្រង់យាងទៅឯព្រះរាជសន្និបាតកុំខាន ព្រោះអាទិទេពយាងមកទាំងអស់ក្តី ហើយខ្ញុំម្ចាស់នឹងរើសយកអ្នកណា ដែលខ្ញុំម្ចាស់ត្រូវចិត្ត ព្រោះជាទេវតានៅស្ថានសួគ៌ក្តី ជាមនុស្សលោកក្តីក៏ពុំហានមកបន្ទោសខ្ញុំម្ចាស់ឡើយ" ។

(មានត)

ដំណើរអស្ចារ្យនៃលោកក៉ាស្ទីយ៉ូយេ

លោកយូក្គុស៊ី រៀបរៀង

លោកប៉ាយ-ប៊ុក ក្រុមការ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

## ២.— ដំណើរទៅកាន់សម្បូណ៌ប្រទេស

(Pays d'Abondance)

លោកក៉ាស្ទីយ៉ូយេ បានបណ្ដោយឲ្យសត្វក្រសារនោះហោះទៅលើអាកាសតាមទំនើងចិត្ត ចម្ងាយប្រហែលម្ភៃឬសាមសិបពាន់យោជន៍ ៗ ដល់អវសាន, លោកបានអញ្ជើញទៅដល់ប្រទេសមួយទៀត, លោកក៏ទាញក្រសារឲ្យចុះទៅទីនោះ ៗ លោកបានឃើញមនុស្សជាច្រើនស្លៀកពាក់ស្អាតបាត ហើយមានទ្រង់ទ្រាយសមរម្យជាងអមតបុរី ៗ គេមិនបានឃើញពួកទុគ៌តអត់ឃ្លានឡើយ ៗ

នៅក្នុងព្រះរាជធានីនៃប្រទេសនោះ លោកបានឃើញស្ពានមួយមានបង្កាន់ដៃលាបប្រេងខ្មៅស្រោបប្រាក់ ៗ គេហដ្ឋានទាំងអស់មានសុទ្ធតែទ្បានមានផ្លូវខ្វាត់ខ្វែង ក្រាលសុទ្ធតែប្រាក់ទឹងមាសមានជណ្ដើរចុះឡើងធ្វើពីអង្កាំ : គេហដ្ឋានទាំងអស់មានសសរចនាដោយត្បូងមានពណ៌ក្ង ចាំងថែង ( agathe ) ផ្ទាំងធ្វើនឹងត្បូងខៀវផ្ទៃមេឃស្រស់ (lapis lazuli)

ហើយមានក្រុងសំណាញ់ធ្វើពីផ្កាថ្ម, មានទ្វារលាបព្រែងក្រហម, មានរបងព្រាក់ ៗ ពាណិជ្ជស្ថាន មានរាំងននក្រហមខ្មៅ មានផ្ទាក់ជាអក្សរមាសនូវនាមព្រមទាំងពាក្យថា "តម្លៃលែងប្រែប្រួល" ឬ "លក់ឲ្យប្រាក់ដល់ដៃ" ព្យួរក់ជាវង់រៀងមូល ៗ លោកហ៊ុស្សបិយូយេ ស្មានថាលោកទៅដល់ស្ថានសួគ៌ហើយ បានសួរនាយពាណិជ្ជម្នាក់អំពីនាមនៃប្រទេសនេះ ៗ ក្នុងពេលនោះ មានមនុស្សព្រឹទ្ធបីនាក់ ស្លៀកពាក់ដោយសម្បូណ៌ភាព ហើយមានទ្រង់ទ្រាយសមរម្យសួរលោកថា "អញ្ជើញមកពីប្រទេសណា?" ៗ ដល់លោកមានប្រសាសន៍ថា លោកមកពីប្រទេសជប៉ុន ៗ អ្នកម្ចាស់ផ្ទះទុកចិត្តឥតសង្ស័យ ទើបស្រែកសួរថា: "អ្នកអញ្ជើញមកពីប្រទេសនោះ ដែលមានសុទ្ធតែមនុស្សស៊ុបរិតដូចជាមនុស្សនៅក្នុងប្រទេសចិនដែរឬ? ខ្ញុំមានចិត្តសង្ឃឹមថាលោកមុខជាអញ្ជើញទៅនៅគេហដ្ឋានរបស់ខ្ញុំ ក្នុងពេលដែលលោកនៅក្នុងសម្បូណ៌ប្រទេសនេះ ហើយលោកមុខជាមានប្រសាសន៍ពីដំណើររបស់លោកដែលមកកាន់ទីនេះប្រាប់យើងផងមិនខាន" ៗ

លោកហ៊ុស្សបិយូយេ បានស្ថិតនៅក្នុងប្រទេសនេះ រាប់សាមសិបឆ្នាំព្យាយាមស្រាវជ្រាវនូវទំនៀមទម្លាប់ប្រពៃណីនៃប្រទេសនេះ ដែលគ្មានអ្នកណារកស៊ីធ្វើការអ៊ីសោះឡើយ ៗ ស្រូវសាលី, សណ្តែកដុះពាសពេញច្រើនជាអនេក គ្មានអ្នកណាដាំ, ថែទាំរក្សាទេ ៗ អ្នកទាំង

អស់អាចយកមកប្រើប្រាស់បានតាមចិត្ត   គេអាចយកទឹកពីទុកយន្ត ( ម្យូនទឹក )  មកបរិភោគបាន ។  មានស្ទឹងប្រែងហូរចុះពីលើខ្នងភ្នំ, ប្រនេះបង្កៀងស្រោបថ្មដូចជាស្លែ (lichens), ចំណែកខាងទៀត ដុះដូចដើមត្រែងពាសពេញបឹង, ត្រពាំងដែលប្រមូលហូរចូលទៅទីងទេទ្រស្រាទំពាំងបាយជូរ  មានដើមកានអណ្តែតជាច្រើន ។  មានគុម្ពោតបន្ទុះដុះនៅក្នុងចម្ការស្កផ្ទុំ,  ត្រពាំងស្រាធ្វើពីផ្លែឈើទុំ  ត្រពាំងស្រាសាកេ (saké) ប្រកពមេរ័យ ។ មាសប្រាក់មានពាសពេញនៅតាមខ្សាច់ស្ទឹង ត្រពាំងត្បូងខៀវផ្ទៃមេឃ ត្បូងគ្រប់ពណ៌ ផ្កាថ្មដែលលំបាកតែរើសប៉ុណ្ណោះ ។ គេបានឃើញមានគុម្ពោតឈើ  មានសុទ្ធតែទំហើយទីរុក្ខជាតិតូចៗ ល្អ  មានផ្លែកល់ឆ្នាំ  សុទ្ធតែដំណាប់វែង ។ គេស្តាប់ឮសត្វស្លាបពីរេះអស្ចារ្យ  ក្នុងទិសាយៈរដូវ,  របងពាំងប៉ុន្មានទៅជាមានផ្កាសុទ្ធតែកំណាត់សំពត់ទឹកនៃស្រង់ពោះគោ  ។  ចំណែកខាងគិរីវិញមានដើមឈើស្លូត្រដុះពាសពេញ  ហើយមានស្លឹករចនាប្រមូលជាអាវ·វែងប៉ាក់  ប្រែសភាពទៅតាមរដូវ  ហើយប្រជាស្ត្រីចូលមករើសយកទៅពាក់តាមត្រូវការ ។ ប្រជាស្ត្រីទៅប្រទេសនេះ  សម្បូណ៌ដោយកោកទ្រព្យគ្រប់បែបគ្រប់យ៉ាង, មិនមានប្រាថ្នាចង់បានអ្វីទៀត, តែសូមកុំឲ្យព្យុះសង្គ្រាមមកបំផ្លាញបុប្ផានៅក្នុងឧទ្យាន,  ហើយគ្មានព្រួយបារម្ភអ្វីគ្រាន់តែព្រួយនឹងពពកបាំងលំអនៃព្រះចន្ទប៉ុណ្ណោះ  ។

នៅក្នុងប្រទេសនេះសុខស្រួលគ្មានសេចក្ដីក្រខ្សត់ ទាំងគ្មានលំបាកនឹងធ្វើកិច្ចការទាំងពួងទេ, លោកវ៉ាសូប៊ីយូយេ បានដើរលេងកំសាន្តសប្បាយរាល់ថ្ងៃជាមួយនឹងមិត្តរបស់លោកបួនប្រាំនាក់ ហើយបរិភោគម្ហូបអាហារៈទៅតាមពលស្រែ ហើយមានតែវត្ថុធ្វើឲ្យរីករាយនៅជុំវិញខ្លួន ។

ប៉ុន្ដែពីរបីឆ្នាំមុន មានពួកវិញ្ញូជនមកពីប្រទេសឥណ្ឌា ហើយបានបង្ហាត់បង្រៀនប្រជារាស្ត្រក្នុងប្រទេសនេះ អំពីលទ្ធិខាងពួកសន្តបុគ្គលថា: "សេចក្ដីសប្បាយរបស់មនុស្សមកពីមានទុក្ខ, ជីវភាពរបស់មនុស្សដែលសុខស្រួលទៅបាន មកពីអ្នកក្រប្រាថ្នាចង់មាន នឹងមកពីពួកសាមញ្ញជន ចង់ឡើងទៅកាន់ឋានៈខ្ពស់ក្នុងសង្គម; ការសប្បាយបំផុតនៅត្រង់កិច្ចព្យាយាមទៅរកវត្ថុមួយ ដែលមិនងាយអ្នកណាបានទៅដល់ ព្រោះសុភមង្គលពិតស្ថិតនៅតែក្នុងប្រទេសណា ដែលមានស្ថានភាពស្ថិតនៅជាកណ្ដាល រវាងសេចក្ដីក្រនឹងសេចក្ដីមាន; សេចក្ដីក្រដែលរាំងរាមនុស្សមិនឲ្យប្រព្រឹត្តបាបលាមក ហើយកិច្ចដែលចង់សប្បាយ ដោយចង់បរិភោគអាហារឆ្ងាញ់ ប្ដូរស្លៀកពាក់ខោអាវថ្មី ត្រូវគិតដល់ការលំបាកក្នុងកិច្ចស្វែងរកទ្រព្យសម្បត្តិ" ។ លទ្ធិទាំងនេះ នាំឲ្យប្រជារាស្ត្រនៅសម្បូណ៌ប្រទេស រំភើបញាប់ញ័រជាខ្លាំង ហើយពួកនេះទៅជាស្រេកទឹកក្លែកដោយចិត្តគិតថា ខ្លួនមិនដែលជួបប្រទះនឹងសេចក្ដីលំបាកសោះ ។ ព្រោះហេតុដូចនេះ បានជាប្រជារាស្ត្រនៅប្រទេសនេះ

បាននាំគ្នាស្អាងព្រះវិហារមួយធំទូលាយនៅក្នុងភូមិក្រៅ នៃព្រះរាជធានី ហើយគេគោរពព្រះអាទិទេពនៃទុគ៌តភាព (le Dieu de la pauvreté) ។ ក្នុងថ្ងៃចូលឆ្នាំជាបឋមនឹងក្នុងថ្ងៃបុណ្យធំៗ គេតែងសូត្រធម៌សូមឲ្យព្រះអាទិទេពនេះ នាំសេចក្ដីក្រខ្សត់មកឲ្យ, ហើយដល់ថ្ងៃអវសានចូលឆ្នាំ គេព្យាយាមដេញចេញពីគេហដ្ឋាន នូវព្រះអាទិទេពទាំងប្រាំពីរអង្គនៃសុភមង្គលនឹងជោគវាសនាល្អ, តែកិច្ចទាំងនេះមិនបានផល; ប្រជារាស្ត្រក្នុងប្រទេសនេះនៅតែមានភោគទ្រព្យដដែល ។ ពួកជនទាំងនេះគ្មានចិត្តសប្បាយរីករាយនឹងការសម្បូណ៌សប្បាយសោះ ។ លោកក៏ស៊ូប៊ីយូយេ អផ្សុកខ្លាំងហើយក៏លអ្នកម្ចាស់ផ្ទះជិះក្រសារបោះតម្រង់ទៅទិសបស្ចិម ។

## គតិអ្នកនិពន្ធ

ពួកនេសាទដែលរកទទួលទានចិញ្ចឹមជីវិតកណ្ដាលសមុទ្រ មិនមែនជាអ្នកលំបាកទេ, ហើយមនុស្សទ្រិទ្រានៅលើគ្រែដែលមានកម្រាលសំពត់សូត្របាក់ដោយឱនមាសប្រាក់ មិនមែនសុទ្ធតែជាអ្នកសុខស្រួលសប្បាយឡើយ ។ សុខហើយនឹងទុក្ខមិនមែនមកពីមានភោគទ្រព្យនឹងក្រសម្បត្តិទេ ។ អ្នកណាដែលប្រព្រឹត្តធ្វើបុណ្យកុសល អ្នកនោះឯងសុខសប្បាយ ។ អ្នកក្រ (ពួកទុគ៌តបុរស) អាចស្វែងរកនូវសុភមង្គលបាន បើអ្នកនោះព្យាយាមធ្វើការឲ្យពេញកំឡាំង ហើយអាចសម្រេចកិច្ចនោះទៅតាមវិត្តបំណងក្នុងជីវភាព ទៅតាមលក្ខណ្ឌរបស់ខ្លួន; តែអ្នកណាដែល

គ្មានបំពេញករណីយកិច្ចរបស់ខ្លួនហើយរស់នៅក្នុងជីវភាព ប្រកបដោយ
កាមារម្មណ៍នឹងតណ្ហា ប្រាថ្នាមិនចេះឆ្អែតស្កប់ស្កល់ ទាំងមានទាសាទាសី
ចោមរោមជាបរិវារ អ្នកនោះមិនទាន់ឈ្មោះថាសុខសប្បាយទេ ។
សប្បាយមកពីលំបាក ហើយលំបាកមកពីសប្បាយ ។ ទឹកស្ទឹងដែលហូរ
មានសភាពបរិសុទ្ធស្អាត, ទឹកដែលនឹងមិនហូរ ច្រើនល្អក់ខ្វក់ខ្វល់ ។
បក្សា, មច្ឆជាតិ, ខុទ្ទកសត្វ (Insectes) ព្យាយាមរកចំណីអាហារមក
ទុក ព្រោះគ្មានវត្ថុអ្វីនឹងបរិភោគ, ពួកសត្វទាំងអស់នោះធ្វើការគ្មានឈប់
ឈរអ្វីឡើយ, ព្រោះហេតុដូចនេះបានជាសត្វទាំងអស់នោះរស់នៅជាសុខ
សប្បាយ ។ តែពួកបសុសត្វ; សេះ, ឆ្កែ, ឆ្មា, មាន់, ទា ដែល
គេចិញ្ចឹម ទៅជាមានជម្ងឺច្រើន ព្រោះសត្វទាំងនោះរស់នៅឥតបានធ្វើ
ការអ្វីឡើយ ។ ដោយមនុស្សចេះស្វែងរកអាហារនឹងសំពត់ខោអាវបំរុង
ទុកបរិភោគនឹងស្លៀកពាក់ បានជាមនុស្សបង្ហាញនូវសភាពថ្លៃថ្នូរជាង
សត្វតិរច្ឆាន ។ អ្នកមានច្រើនស្លៀកពាក់ខោអាវនឹងបរិភោគអាហារមិន
ដឹងប្រមាណ, ព្រោះហេតុដូចនេះ បានជាអ្នកមានច្រើនមានជម្ងឺ ។ ប្រាជ្ញា
បើមិនព្យាយាមទេ ទៅជាមានសភាពអន់ថយ; រូបកាយមិនហាត់ទៅជា
ខ្សោយ មានអាពាធ ។ បើទុកជាមានភោគទ្រព្យយ៉ាងណាក៏ត្រូវតែធ្វើការ
ដូចជាអ្នកក្រខ្សត់ដែរ នេះហើយដែលជាឱសថសម្រាប់ធ្វើកាយឲ្យមាន
សុខភាពដ៏បរិបូណ៌ ព្រមទាំងចិត្ត ប្រកបដោយហសនៈរីករាយតាមត្រូវការ ។

(មានត)

## ដំណើរតាមខ្យល់ក្នុងកម្មដ្ឋានៈ

## លោក ផេង-ជ្រឹវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

លោកអែយ៉ាជជាបិតា ក្រឡេកឃើញកូនលោកមានការផ្លាស់ប្តូរកិរិយាដូច្នោះ ក៏ភ្ញាក់ខ្លួនព្រើត ប្រហែលលោកតូចចិត្តខ្លាំងណាស់ ដោយគិតថា កូនលោកគ្រាន់តែឃ្លាតពីស្រុកប៉ុន្មានឆ្នាំ ស្រាប់តែលះបង់ទំនៀមឪពុកម្តាយចោលអស់ ។

លោកអែយ៉ាជមានជន្មាយុជិតចិតសិបឆ្នាំហើយ លោកដឹងថា ខ្លួនលោកបានរស់នៅជាយូរអង្វែងហើយ ប្រហែលមិននៅរស់បានប៉ុន្មានទៀតឡើយ ។ តើពន្លឺថ្មីនឹងមានដល់បូព៌ាប្រទេសឬទេ? តើលោកនឹងបានឃើញសម័យថ្មីនេះ មុនពេលដែលទៅកាន់ទីសម្រាកឥតវិលត្រឡប់ឬទេ? ។

លោកមិនហ៊ានថ្លែងមុនសេចក្តីយល់ ទាំងមិនហ៊ានឆ្លើយប្រាប់ការណ៍ពិតការណ៍មែន ប៉ុន្តែបើតាមហេតុភេទស្រុក ហាក់ដូចជាបុរងនឹងត្រូវតាមសេចក្តីយល់ដ៏ពីអតីតកប្បហើយ ។ លោកអែយ៉ាជបារម្ភពេក ខ្លាចក្រែងការសង្ឃឹមរបស់លោកកើតអុកឡុកនូវបណ្តាគំនិតអាក្រក់នៃពួកអឺរុប ក្នុងវេលាមុនលោកអនិច្ចកម្ម ។

ដោយអំណាចសប្បុរសធម៌និងការពិសោធន៍កន្លងជីវភាពដែលលោកបានសន្សំ និងបានប្រទះតាំងពីសក់ខ្មៅដល់សក់ស លោកមិនបានសំដែងអាការមិនពេញចិត្តចំពោះការផ្លាស់ប្តូរទំនៀមទម្លាប់និងសេចក្តីស្នេហាដ៏ស្ងាត់ៗ ចំពោះប្រទេសបច្ចិមា របស់កូនចៅលោក ឲ្យឃើញជាក់ច្បាស់ឡើយ ។ លោកមានសាសនាមហាម៉ុតជាទីពឹង ជាសាសនាមួយខាងបូព៌ាប្រទេស ដែលគេសន្មតទុកថាប្រកបនៃសប្បុរសធម៌និងជាឧបាយដ៏ពិតទៀងត្រង់សម្រាប់ខ្លួនទៅកាន់ស្ថានសុគតិបាន ។ លោកយល់ច្បាស់ថា ជីវភាពតែងដឹកនាំមនុស្សទាំងឡាយ ហើយគ្មានអ្នកណាអាចទប់ទល់នឹងហេតុគេទបានឡើយ បើចង់សុខ គ្រាន់តែកុំព្រួយរវល់នឹងការណ៍នោះពេកក៏បានហើយ ។

លោកតែងមានប្រសាសន៍ជាញឹកញយថា អ្វីដែលត្រូវមាន គង់នឹងមានមកដល់, សូមឲ្យបំណងនៃព្រះអាឡស់បានសម្រេច ហើយយើងគ្រប់គ្នាត្រូវថ្វាយពរចំពោះព្រះអង្គ ដែលបានសំដែងនូវហេតុគេទឲ្យយើងឃើញ ។

មានមនុស្សជាច្រើនដែលមានសេចក្តីទុក្ខវេទនាជាងយើង គឺអ្នកក្រដើរសូមអង្ករសូមបាយទំ តាមផ្លូវដើម្បីបង្អន់ការស្រេកឃ្លាន ។

ពួកមិត្រភក្តិ ពួកមាត់ស្រមូមដែលអង្គុយនៅជុំវិញងក់ក្បាលព្រមគ្នាទទួលតាមយោបល់លោកកៃយ៉ាង ។ ជនទាំងនោះជាទាហ៊ុនចាស់ស្រុក

ជាបរិស័ទចិត្តស្មោះត្រង់ចំពោះព្រះអាឡស់ ជាមនុស្សសុចរិតហើយមាន ច្បាប់ប្រកាន់លទ្ធិថា ក្នុងជីវភាពមិនត្រូវឲ្យខុសទៅលើឈ្មោះណា ៗ ពួកកស្ត្រប្រែជា តាំងពីអ្នកមានសម្បត្តិទ្រព្យ រហូតដល់អ្នកក្រខ្សត់តែង កប់អានជនចាស់ស្រុកទាំងនោះ ហើយនាំគ្នាលើកតំកើងលទ្ធិនោះថា ជាលទ្ធិឧត្តុង្គឧត្តម ។

ពួកចាស់ព្រឹទ្ធាចារ្យក្នុងស្រុកទាំងប៉ុន្មាននាក់ តែងមកប្រជុំគ្នានៅ វេលាថ្ងៃរសៀលនៅកន្លែងទទួលភ្ញៀវ ក្នុងផ្ទះលោកអែយ៉ាដ កាលណាស្មើព្រះអាទិត្យចាំងមកយ៉ាងក្តៅលើដី ធ្វើឲ្យសូរស័ព្ទផងទាំងពួង ស្ងៀមស្ងាត់ឈឹង ដូចសមុទ្រវេលាស្ងប់ខ្យល់ ។ កន្លែងនោះគឺជា បន្ទប់មួយដ៏ធំទូលាយ ដែលបង្អួចសំណាញ់បើកចំទៅលើសួនមួយ សុទ្ធតែដើមត្នោតនឹងផ្កាកុលាបដើម ។ ជញ្ជាំងបាំងដោយព្រំដ៏មានតម្លៃ ដែលត្បាញជាព្រៃឈើនឹងសរសៃសូត្រពណ៌លឿងទុំ លាយចំរុះនឹង សំពត់កាំម៉ូពណ៌ក្រហម មានបក្សីបក្សាពណ៌យ៉ាងឆើតហើរឆ្វៀលឆ្វាត់ ប្រចិកគ្នាខាងក្នុង ។ ព្រំនេះគេទិញមកពីប្រទេសស៊ីណ៍ ។ ឯពិតាន មានបង្អៀងគោមស្អាតធំៗ ក្អមទាំងអស់សុទ្ធតែប្រេងក្រអូបព្យួរសើគោកមក ។

នៅឯក្រោម លើឥដ្ឋ ក្រាលសុទ្ធតែព្រំនឹងកន្ទេលក្រហមពាស ពេញដោយខ្នើយៈ ខ្នើយកែប ខ្នើយកូន ខ្នើយថ្នាក់ថារ នឹងពូកទ្រនាប់ តូចធំ ហើយមានមនុស្សបំរើម្នាក់ចាស់ឈ្មោះគាឡប ចិត្តស្មោះត្រង់ចំពោះ

នាយចៅហ្វាយ នៅនឹងផ្ទះលោកអៃយ៉ាជតាំងពីកើតដល់ធំមិនដែលឃ្លាត ចេញទៅទីណា ជាអ្នកបំរើខាងទឹកតែ ប៉ាន: ផ្ដើផ្លែផុឡើក ផ្លែក្រូច ពោធិ៍សាត់ដាក់ក្នុងកែវពែងចរណៃទឹងទំផ្សេង ៗ ដាក់ក្នុងចានទៀបសត្វាំង យកមកតម្រៀបលើតុៈមួយទាប ក្រហមក្រមៅវិចិត្រដោយក្បាច់របនា ទឹងក្លុក ៗ

ក្នុងវេលាដែលពួកមិត្តសំឡាញ់កំពុងនាំគ្នាបរិភោគទឹងផឹកបាន: ក្តៅ ឬត្រជាក់ទឹងទំមានឧជារស លោកអៃយ៉ាជគន្ធ័យជក់ខ្សៀរទឹកក្រអូប បង្ហុយផ្សែងកុយ ៗ ផ្សែងនោះមិនយូរប៉ុន្មានក៏ហុយទៅជួបហើយលាយឡំជាមួយផ្សែងខ្ទឹមចន្ទន៍ក្រស្នា ដែលបំពក់ក្នុងហិងឡូវស្ពាន់ជានិច្ចកាល តាំងពីព្រលឹមដល់ថ្ងៃលិច ៗ

លុះផឹកស៊ីរួចហើយ ភ្ញៀវទាំងនោះនាំគ្នាជំណាលរឿងផ្សេង ៗ ច្រើនយករឿងជាទីគាប់ចិត្តនៃខ្លួនមករ៉ាយរ៉ាប់ គឺចូលចិត្តលើកយករឿងចាស់ ៗ ពីឆ្នាំមុន ៗ រឿងពីកាលខ្លួននៅក្មេង ៗ មកប្រៀបធៀបនឹងរឿងសម័យបច្ចុប្បន្ន ហើយឃើញថាសម័យពីបុរាណបានសុខសប្បាយជាង ៗ ជនទាំងនោះដែលពោលរឿងអស់នេះ ច្រើនប្រើសំដីសុភាពស្ងៀមៗ ស្មើរដូចរូបអ្នកតា មិនសំដែងអាការកម្រើកដៃជើងឡើយ ប្រហែលគ្នានឹងអ្នកប្រឹងស្មាធិ៍ហើយបានសម្រេចមគ្គផល នឹងបានស្ថានបរមសុខធុតតាកកន្ទល់ក្នុងលោក ៗ

*
* *

ថ្ងៃនោះ សៀមជាកូនប្រុសរបស់សំឡាញ់លោកអៃយ៉ាដទើបនឹងចូលមកក្នុងទីប្រជុំ, ខាងក្រោយដែលបានធ្វើគារវកិច្ចចំពោះចាស់ព្រឹទ្ធាចារ្យរួចហើយ សៀមក៏ទៅអង្គុយក្បែរមេក្តាជាសំឡាញ់ ។ អ៊ីស្មាអ៊ីលក៏ចូលមកក្នុងបន្ទប់នោះដែរ ។

អ៊ីស្មាអ៊ីលស្លៀកពាក់ឯកសណ្ឋានទាហានសេះ ក្រឡាបត្រង់ខ្មៅ យ៉ាងសង្ហាស័ក្តិសម ដៃពាក់ស្រោម កាន់កាតិបមួយលំអដោយសែសយប្រាក់ នឹងកាន់រំពាត់ខ្សែតីមួយផង ។ គេខុនគំនាប់ជារបៀបអាក៉ប់ដល់ឪពុកគេជាមុន គឺយកដៃដាក់ត្រង់ថ្ងាស ហើយដាក់ត្រង់បបូរមាត់ រួចស្ទាបត្រង់បេះដូងជាទីបំផុត ។ រួចពីគារវកិច្ចចំពោះឪពុក គេចាប់គំនាប់ភ្ញៀវជាបន្ទាប់ បែរវិលជុំវិញខ្លួនហើយស្ទុះក្លែតទៅអង្គុយប្រកៀវលើកូនកៅអីឫស្សីមួយដែលដាក់នៅក្បែរជញ្ជាំង ។

ខណៈនោះ បរិយាកាសពេញដោយរហសភាព ហាក់ដូចជាដំណើរដែលអ៊ីស្មាអ៊ីលចូលមក បណ្តាលឲ្យស្ទះការចរចារវាងពួកភ្ញៀវទាំងអស់មិនឲ្យនិយាយរួច ។

ពួកភ្ញៀវទាំងអស់ ឈប់ទទួលស្គាល់អ៊ីស្មាអ៊ីលដែលស្លៀកពាក់ជាបែបទាហានសេះយ៉ាងស័ក្តិសម កងស្ងើង ថាជាមនុស្សមានសញ្ជាតិជាមួយ, តែដែលតាមការពិត មនុស្សក្នុងទីប្រជុំនោះសុទ្ធតែមានសញ្ជាតិតែមួយ គឺសុទ្ធជាអ្នកផឹកទឹកតែក្រអូប ទាំងស្លៀកសំពត់ដោយរុំដូចៗគ្នា ។

អ៊ីស្លាអ៊ីល មាត់បែបមានសាច់ហើយឡើងក្រហម ច្រមុះត្រង់ស្រួច បបូរមាត់បង្ហាញនឹងថ្ពាល់គោះយ៉ាងរលីង មានដាក់ម្សៅស្តើងព្រាលៗដើម្បីបំបាត់ស្រមោលខៀវៗនៃស្បែក ។

ហេតុបន្តិចបន្តួចអស់នេះមិនល្មមនឹងយកជាការណ៍បានឡើយ ប៉ុន្តែពួកមិត្តភក្តិលោកអែយ៉ាដនៅតែមិនពេញចិត្តសោះ ។

អើ! ប្រាកដមែន! អ៊ីស្លាអ៊ីលផ្លាស់ប្តូរអស់ហើយ ដែលទើបនឹងមកពីប្រទេសអឺរ៉ុប ហើយជាការដែលនាំឲ្យលេចផ្សេងខ្លាំង, ដ្បិតក្នុងចំណោមនោះ មនុស្សស្លុតបែបចាស់ៗក្នុងស្រុក ជាអ្នកកាន់ទំនៀមទម្លាប់យ៉ាងម៉ឺងម៉ាត់ចំពោះសាសនាឥស្លាមផង ។

រស្មីមេបេនអាប់ដាឡស់ ក្នុងអំឡុងប្រហែលដប់ឆ្នាំមុន ជាគូកនជាមួយនឹងអ៊ីស្លាអ៊ីល ធ្លាប់លេងល្បែងជាមួយគ្នា តែងនាំគ្នាទៅក្នុងព្រៃយកសំបុកចាប កាច់ឃ្មុំ ឬក៏នាំគ្នាទៅលបលាក់ខ្លួនពួនខាងក្រោយដុំថ្មយ៉ាងស្ងាត់ ចាំលួចមើលនារីអារ៉ាប់ដែលនាំគ្នាស្រាត ហើយចុះលាតងូតទឹកជ្រោះស្រែកហ៊ោកញ្ជ្រៀវ ហើយឡើងមកវិញ ជូតខ្លួនប្រាណស្អាត បាតនាំគ្នាដើរដង្ហែមុខក្រោយជាជួរ ទូលក្អមទឹកមួយម្នាក់ត្រាច់តាមផ្លូវដើរដ៏ចង្អៀត រស្រែកច្រៀងកាយទំនុកបែបបង្អូសៗ គួរឲ្យស្រណោះស្រណោចពេក នាវេលាថ្ងៃទៀបហៀបចូលរនូ ។

ឱ! គួរស្រណោះសេចក្តីរីករាយដ៏សុខមក្នុងវ័យកុមារភាព! គួរស្តាយមិត្តភាពក្នុងវ័យដប់ប្រាំឆ្នាំ ឱគួរស្តាយពេក! ជីវភាពដែល

ប្រព្រឹត្តទៅតែងបំបែកស្ទើរតែជាធម្មតា នូវមិត្តសំឡាញ់ក្នុងកាលជាតរុណភាព ។

ហេតុភេទតែងមានកម្លាំងខ្លាំងជាងមនុស្សជានិច្ច ចំណែកការដ៏សុភាព ក្រមទឹងតាំងនៅស្មើភាគគ្នាទៅវិញទៅមកបានណាស់ ។

កាន់តែធំចំរើន កាន់តែបានស្គាល់សេចក្តីពិសោធន៍យ៉ាងច្រើន អំពីសត្វទឹងសង្ខាររាល់តែឆ្នាំ យើងគ្រប់រូប តែងត្រឡប់ផ្សេងចាកគំនិតដើមដែលបានគ្រោងទុកក្រមានណាស់ មនុស្សដែលអាចរក្សាពាក្យក្នុងកាលជាកុមារភាពទុកបានមិនឃ្លៀងឃ្លាត ។

រឿងដែលនិយាយមកនេះ តើឲ្យផលខាងល្អ ឬខាងអាក្រក់? ការណ៍នេះត្រូវស្ទះទុក កុំសំរេចសេចក្តី, ស្រេចលើព្រេងវាសនារបស់យើងជាអ្នកតាក់តែងមកឲ្យសុខឲ្យទុក្ខ ។ ស្រេចលើព្រះអាឡស់ដែលជាតួសេចក្តីល្អគ្មានទីបំផុត ជាអ្នកមេចំណែកស្រាប់ ។

*

* *

អ៊ីស្មាអ៊ីលបានចេញចាកក្រុងតូច ឈ្មោះកាសិ · កាពប៊ូលី តាំងពីអាយុដប់ប្រាំបីឆ្នាំ ដើម្បីទៅរៀនសូត្រចំណេះវិជ្ជាឯប្រទេសអឺរ៉ុប ហើយដើម្បីធ្វើឲ្យបានស្ទាត់ក្នុងភាសានៃជនបរទេសក្នុងរវាងបីឆ្នាំ គេបានទំសិក្សាផ្នែកខាងវិជ្ជាពាណិជ្ជកម្មនិងសិប្បយការ ដែលជាវិជ្ជាបានបង្ហើបគំនិតប្រាជ្ញាអ៊ីស្មាអ៊ីលទៅលើសាកលលោក ដែលនៅកំបាំងមកយូរ

ហើយ  នឹងជាវិជ្ជាដែលធ្វើឲ្យគេមានប្រាជ្ញាដ៏ធំទូលាយដល់សាសន៍នៅខ្ញី តែខ្លាំងប៉ិនប្រសប់ក្នុងផ្លូវចាត់ការផ្សេងៗ ។

ឯសៀមបេនអាប់ជាឡស់  មិនដូច្នោះឡើយ  នៅតែនឹងទីក្រុងកំណើតនៃអាត្មាក្បែរឪពុក ហើយលុះឪពុកអនិច្ចកម្មទៅ ខ្លួនក៏ឡើងបានជានាយកក្នុងក្រុមញាតិជំនួសឪពុក  ម៉្លោះហើយទើបកើតមានអស្មិមានះកាន់តែច្រើន  ហើយថែមទាំងខំចិញ្ចឹមសេចក្ដីគោរពចំពោះទំនៀមទម្លាប់ពីបុរាណឲ្យរឹតតែធាត់ធំផង ។

សៀមបណ្ដោយឲ្យពុកចង្កាដុះតាមបុរាណសម័យនិយម  ហើយពេមខ្មៅៗ ដែលដុះព័ទ្ធជុំវិញមុខ  រឹតតែសំដែងទឹកមុខថាជាមនុស្សមានសេចក្ដីម៉ឺងម៉ាត់  ព្រមទាំងយង់ឃ្នង,  បបូរមាត់ស្ដើងនឹងចិញ្ចើមក្រាស់បង្ហាញឲ្យស្គាល់ចរិតឆាប់ខឹងនឹងមុខរឹង  ហើយបើប្រឡាក  គ្មាននរណាអាចបន្ទន់បាន,  ចំណែកទស្សនាការ  បើក្រឡេកទៅខាងណាអាចនិយាយប្រាប់ថាជាអ្នកល្មោភលោភលន់  នឹងប្រណែនឈ្នានីះយ៉ាងធំ  ព្រោះមានសេចក្ដីស្ដាយដែលខ្លួនមិនបានធ្វើជានាយកបណ្ដាច់នៃជនជាតិអាក៉ប់នាក្រុងកាសិ-កាពប៊ូលី ។

ហេតុដូច្នេះ  បានជាសៀមខំការពារហានទ្ដរៈដែលត្រូវបានមកលើខ្លួនទុក  ហើយសព្វថ្ងៃនៅឯផ្ទះ  គេគ្មានធ្វើការៈអ្វីក្រៅពីបង្វឹកការរៀនប្រើអំណាច  លុះប្រើយូរៗ ទៅរហូតដល់គ្មានសប្បុរសធម៌ក្នុងខ្លួន ។

ស្រីមចូលចិត្តឲ្យតែអ្នកដទៃធ្វើតាម នឹងត្រូវតែស្តាប់បង្គាប់ គេបង្កើតទំនៀមមួយថាជនណាក៏ដោយ មិនត្រូវមានសិទ្ធិនឹងទទឹងទាស់នឹងសំដីរបស់គេទេ ហើយការណ៍ដែលគេចំសំដែងទឹកមុខស្រពយពក់ទាក់ចំពោះសាស្នគ្នី ដ្បិតគេនឹកថាពួកគ្នីនឹងមិនលែងគិតថាគេជាមនុស្សមួយ ហើយទៅថ្ងៃមុខនឹងឲ្យផ្ទាន់ជាយសសក្តិអ្វីមិនខាន ។

ម៉្លោះហើយការឆ្មើងឆ្មៃនឹងអភិជ្ឈាធម៌បណ្តេញសេចក្តីស្នេហាចំពោះស្រុកទេសចេញពីក្នុងខ្លួនអស់ ម្យ៉ាងទៀត ប្រហែលនៅក្នុងខ្លួនគេមានធម៌កំសាកមួយពីកំណើត ដែលតែងធ្វើគេឲ្យត្រូវតែឱនលំទោននៅចំពោះមុខជនមានកំឡាំងជាង ។

សេចក្តីទោរទៅនៃចរិតបែបនេះផង ការបាត់មុខនៃអ៊ីស្មាអ៊ីលដែលធ្វើដំណើរទៅក្នុងប្រទេសអឺរុបជាយូរឆ្នាំផង ធ្វើប្រឡាយដ៏ជ្រៅហើយធំឃាំងអ្នកកំឡោះទាំងពីរ ។

ចំណែកអ៊ីស្មាអ៊ីលវិញ តែងចិញ្ចឹមនូវសេចក្តីស្នេហាយ៉ាងមាំចំពោះស្រុកទេស នឹងចំពោះអ្នកណាដែលបានធ្វើសេចក្តីចំរើនរុងរឿងដល់ជាតិ ទុកនៅក្នុងចិត្តជានិច្ច ។ គេមិនបណ្តោយតាមតែគំនិតនាំឲ្យថយក្រោយ ដែលបណ្តាលឲ្យកើតជាគ្រឿងជំទាស់ដល់សម័យនិយមដឹកចុះដឹកឡើងដូចមនុស្សខ្លាក់ទេ ក្នុងខណៈដែលការ្យធម៌នៃប្រជាជនត្រូវស្ទុះចំរើនឡើង ។

អ៊ីស្មាអ៊ីលបានរៀនអាជីវកិច្ចផ្សេងៗ នៃមនុស្សពីបរទេស ហើយព្រមទាំងបានយកនូវការជំរេកចំពោះសេរីភាព វិជ្ជា យុត្តិធម៌ បំណេះ អត់ធុន សាមគ្គីធម៌ពីក្នុងការនៃដំណើរនោះផង ។ រឿងប៉ុណ្ណោះជាគ្រឿងជំទាស់ដល់ជនជាតិក្នុងកន្តារៈ ដែលធ្លាប់ប្រកាន់តែជំរះក្តីតាមច្បាប់អ្នកមានកំឡាំងខ្លាំង គឺមិនតាមច្បាប់អ្នកមានយុត្តិធម៌ឡើយ ។

ហេតុដូច្នេះ ការណ៍ដែលរស្មីមផ្តើមទំលុះរហសភាពដោយសំឡេងយ៉ាងមុត ពួកមិត្តភក្តិនៃលោកអៃយ៉ាដ តាមដោយស្មានប្រហែលពេញចិត្តណាស់ ។

រស្មីមក្រោកឡើង បែរមុខផ្ទោះទៅរកសំឡាញ់ចាស់ ហើយនិយាយដោយពាក្យបំអកថា: "អ៊ីស្មាអ៊ីល! ចូរឯងរៀបរាប់រឿងពីវប្រាប់យើងបន្តិចទៀតមើល! ។ រឿងបរទេស អញចូលចិត្តស្តាប់ពន់ពេក! ធ្វើឲ្យអញសប្បាយអស្ចារ្យ! ។

អ៊ីស្មាអ៊ីលសំឡឹងរស្មីមយូរបន្តិច ក៏ស្គាល់ទឹកមុខសំឡាញ់ចាស់ថាជាអ្នកមានចិត្តព្យាបាទលោកគិតទាន់ភ្លាមថាត្រូវតែប្រែឧបាយទប់ទល់វិញ ទើបឆ្លើយយ៉ាងខ្លីថា: "បពិត្រអស់លោកជាញាតិមិត្រទាំងឡាយ! រឿងប្រទេសអឺរ៉ុបរបស់ខ្ញុំមិនសូវមានប្រយោជន៍ដល់អស់លោកពល់គ្នាទេ" ។

(មានត)

សុន្ទរកថា

# ឯកឧត្តម សម-ញាណ រដ្ឋមន្ត្រីក្រសួងធម្មការ

ថ្លែងក្នុងពិធីអនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃទី ១០ នៅថ្ងៃទី ១៩ ខែមករា ២៤៩៦ ១៩៥៤

អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃនេះ ជាគំរប់ ១០ ឆ្នាំហើយ គិតឆ្នាំនេះ ព្រះមហាវីរក្សត្រចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ៨០០០ រៀល ឲ្យក្រសួងធម្មការចាត់ធ្វើភត្តប្រគេនមន្ត្រីសង្ឃក្នុងក្រុងភ្នំពេញនិងមន្ត្រីសង្ឃដែលនិមន្តមកពីខេត្តនានា ៗ មហាសន្និបាតនេះទុកជាព្រះរាជពិធីរបស់ព្រះករុណាដោយពិត ។

ឯកឧត្តមសម-ញាណ បានពិតទូលព្រះថេរានុត្ថេរៈទាំងឡាយអំពីកិច្ចការខាងពុទ្ធចក្រនិងខាងអាណាចក្រ ដែលក្រសួងធម្មការបានបំពេញក្រោមព្រះរាជាធិបតិភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលយើងដកស្រង់ដោយសេចក្ដីបំព្រួញ សំដៅយកតែត្រង់គោលសំខាន់ៗ ដូចតទៅនេះ ៖

## អំពីពុទ្ធចក្រ

សព្វថ្ងៃនេះ មានសាលាសម្រាប់សិក្សាធម៌វិន័យគឺ: សាលាបាលីជាន់ខ្ពស់នៅក្រុងភ្នំពេញ ១, សាលាបាលីរង នៅខេត្តក្រៅ ៣៣៥ វត្ត, សាលាបាលីរង នៅដែនកូសាំងស៊ីន ១៩ វត្ត ។ សាលាទាំងនេះមានសិស្សានុសិស្សទាំងអស់ ៥.៣៥៤ អង្គ ។

សាលាធម្មវិន័យថ្នាក់ឯកទីដ៏ថ្នាក់ទោ មានតែនៅវត្តៗណាលោម ក្រុងភ្នំពេញ ឯវត្តខេត្រក្រៅមិនទាន់មាននៅឡើយ ។

សាលាធម្មវិន័យថ្នាក់ត្រី មាននៅវត្តទាំងឡាយក្នុងព្រះរាជធានីនិង ខេត្រក្រៅ រួមទាំងអស់ចំនួន ១០៧ វត្ត មានសិស្សរៀនទាំងអស់ចំនួន ១២.០០០ អង្គ ។

ឥឡូវនេះនឹងមានសាលាមួយយ៉ាងប្រសើរ បានរៀបចំកសាងហើយ នៅត្រង់កន្លែងដីផ្សារសួនចាស់ ជាខាងជើងសាលាបាលីជាន់ខ្ពស់ ។ សាលានេះប្រហែលជាដល់ទៅពុទ្ធសករាជ ២៤៩៧ នឹងធ្វើរួចស្រេច ។

អំពីបុព្វហេតុដែលកើតសាលាដ៏ប្រសើរនេះ គឺនៅពេលដែលព្រះ តោជិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ និមន្តត្រឡប់មក ពីប្រទេសថៃវិញ បានធ្វើសេចក្តីរាយការណ៍ថ្វាយ ព្រះពរព្រះករុណា ថានៅប្រទេសថៃមានមហាវិទ្យាល័យពុទ្ធសាសនា ២កន្លែង មានល្បឿន យ៉ាងលឿនក្នុងការសិក្សាពុទ្ធសាសនាទាន់សម័យ ដូច្នេះគួរតែបង្កើត មហាវិទ្យាល័យពុទ្ធសាសនាមួយក្នុងប្រទេសកម្ពុជាក្នុងសម័យនេះ ដើម្បី កុំឲ្យចាញ់ប្រៀបពុទ្ធសាសនានៅប្រទេសថៃ ។

ព្រះករុណាទ្រង់សព្វព្រះរាជហឫទ័យផង ទ្រង់ឲ្យក្រសួងធម្មការ ចាត់ការនេះឲ្យបានសម្រេចតាមព្រះតោជិវង្ស ព្រមទាំងប្រោសព្រះ

ពងទានដីត្រង់កន្លែងផ្សារស្ទួងចាស់នោះ ឲ្យសង់មហាវិទ្យាល័យព្រះពុទ្ធសាសនា ។

ជាសិទ្ធិជោគនៃព្រះពុទ្ធសាសនា បណ្ដាលឲ្យគហបតី បេ-យាន អ្នកជំនួញនៅក្រុងភ្នំពេញ មានសទ្ធាយ៉ាងមុះមុតបរិច្ចាគធនធានផ្ទាល់ខ្លួន កសាងមហាវិទ្យាល័យនេះជាប៉ផ្ទាក់ ដោយគ្រឿងស៊ីម៉ង់តិ៍ដែកបូជាចំពោះព្រះពុទ្ធសាសនា ។

ក្រសួងធម្មការ បានតាំងគណៈកម្មការមួយក្រុម និងគណៈកម្មការរងមួយក្រុមទៀត សម្រាប់រៀបចំកម្មវិធីនៃការសិក្សាជា ២ ផ្នែក:

១– រៀបចំកែប្រែកម្មវិធីនៃការសិក្សា នៅសាលាបាលីជាន់ខ្ពស់ ដោយបន្ថយវិជ្ជាមុខណាមួយចេញ ហើយបញ្ចូលវិជ្ជាថ្មីថែម ឲ្យសមទៅតាមកម្មវិធីសម័យនិយម ។

២ - រៀបចំកម្មវិធីនៃការសិក្សា នៅមហាវិទ្យាល័យពុទ្ធសាសនា ដោយរៀបដំឡើងវិជ្ជាខាងព្រះពុទ្ធសាសនា ឲ្យស្មើនឹងវិជ្ជាខាងផ្លូវលោក ត្រឹមថ្នាក់ដុកទ័រ កំណត់ពេលរៀន ២០ ឆ្នាំ យ៉ាងតិច ។

អំពីគោលបំណងនៃការបង្កើតមហាវិទ្យាល័យ ខាងព្រះពុទ្ធសាសនានេះ ដោយមានប្រាថ្នាឲ្យពួកបព្វជិតជាសិស្សមហាវិទ្យាល័យនេះ បេះដឹងចំណេះវិជ្ជាខាងផ្លូវលោកនិងផ្លូវធម៌យ៉ាងចំណាន គឺជានឹងបណ្ដុះបណ្ដាលពួកសិស្សានុសិស្ស នៃមហាវិទ្យាល័យពុទ្ធសាសនានេះឲ្យបេះ

ដឹងបំណោះវិជ្ជាខាងផ្លូវលោក រួមជាមួយនឹងផ្លូវព្រះពុទ្ធសាសនា ល្មម ប្រើការបានគ្រប់គ្រាន់អាចធ្វើជាធម្មទូតជាតិ នៅក្នុងប្រទេសនឹងក្រៅប្រទេសបាន នាំឲ្យប្រទេសយើងបែរមុខឆ្ពោះទៅកាន់សេចក្តីចំរើនទាន់សម័យ ។

មួយវិញទៀត ឯកឧត្តមសូមធ្វើបញ្ហាមួយចំពោះព្រះសង្ឃថា ព្រះពុទ្ធសាសនាមានធុរៈ ២ យ៉ាងគឺ:

គន្ថធុរៈ ១

វិបស្សនាធុរៈ ១

ឯគន្ថធុរៈប្រទេសយើង បានបំពេញជាលំដាប់មកហើយ នៅតែវិបស្សនាធុរៈពុំទាន់មានសាលាសម្រាប់រៀនដូចប្រទេសភូមានៅឡើយ ។

## អំពីអាណាចក្រ

ឯកឧត្តម បានទូលព្រះសង្ឃគ្រប់ព្រះអង្គថា ស្ថានការណ៍នៃប្រទេសយើង មានអាសន្នគ្រោះថ្នាក់ផ្សេងៗ រាប់ង ៧ - ៨ ឆ្នាំមកហើយ នាំឲ្យប្រជាជនបែកសាមគ្គីគ្នា មិនសូវប្រតិបត្តិតាមច្បាប់សម្រាប់ប្រទេស, អសន្តិសុខកើតមានឡើងជាដរាបមក ។

កាលបើអំពើអកុសលគ្រប់បែបគ្រប់យ៉ាង ធ្លាក់មកលើប្រជាជនរួមជាតិដូច្នេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ស្តេចយាងចេញពីព្រះរាជអាណាចក្រ ដើម្បីបំពេញបេសកកម្មនាបរទេស តាមតារយក

ឯកភាព លុះព្រះអង្គស្ដេចត្រឡប់មកកាន់ព្រះរាជធានីវិញ ទ្រង់ដឹកនាំប្រជារាស្ត្រព្រះអង្គ ដោយព្រះរាជមនោរាប៉ាយដ៏សុខុមឲ្យកើតសាមគ្គីធម៌ លះបង់អស្មិមានះ ស្របតាមនិតិគ្នាស្វាមីភក្តិព្រះមហាវីរក្សត្រ ព្រមព្រៀងស្ម័គ្រចិត្តហាត់ធ្វើជាកងជីវពល កងនារីក្លាហាន តាមផែនការព្រះសីហនុ នាំឲ្យបាពង់អត់ទ្រាំពុំបាន ក៏ព្រមថ្វាយគេតនកណ្ឌនៃឯករាជ្យ ខាងតុលាការ, ក្រុមព្រះនគរបាល (ប៉ូលិស) និងខាងកងទ័ព, ក្រៅពីនេះព្រះអង្គទ្រង់ព្យាយាមទាមទារគេតនកណ្ឌនៃឯករាជ្យដែលនៅសេសសល់ទាំងប៉ុន្មាន ឲ្យបានបរិបូណ៌ក្នុងពេលយ៉ាងខ្លីដោយសន្តិវិធី ។

ទោះបីព្រះនរបតីទ្រង់ធំយ៉ាងនេះ ក៏នៅតែមានមនុស្សអកុសលពោលក្លួតកុហកទៅបាន ដូចមានក្នុងព្រះរាជសាសន៍ចុះថ្ងៃទី ២៥ ទី ២៦ និងទី ២៧ ខែវិច្ឆិកា គ.ស ១៩៥៣ ហើយនិងព្រះសង្ឃប្រកាសនៃសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ បានបដិសេធពាក្យឃោសនាអកុសលនេះសព្វគ្រប់ហើយ ដូច្នេះ សូមព្រះសង្ឃពិនិត្យតាមព្រះរាជសាសន៍និងព្រះសង្ឃប្រកាសទាំងនេះ ហើយសូមជាសំគៀនរំលឹកភិក្ខុ-សាមណេរឲ្យប្រព្រឹត្តតាមធម៌វិន័យ កុំឲ្យមានអធិករណ៍ តាំងនៅក្នុងសាមគ្គីធម៌ ហើយសូមទរមានពុទ្ធបរិស័ទចំណុះវត្តឲ្យនាំគ្នារក្សាសាមគ្គីធម៌ ដើម្បីការពារនូវត្រៃសរណដ្ឋានគឺជាតិ-សាសនា មហាក្សត្រ ឲ្យបានថ្កុំថ្កើងរុងរឿងទៅអនាគត ។

នៅទីបំផុតនេះ ឯកឧត្តមបានលើកយកនូវផលអាគន្តុកទាននេះ ថ្វាយចំពោះព្រះករុណា ហើយទឹងសូមបួងសួងដល់ទេវតាទាំងឡាយឲ្យ ជួយការពារថែរក្សាព្រះមហាក្សត្រ ឲ្យស្ថិតនៅជាបរមសុខក្នុកសិរីរាជសម្បត្តិដកបដល់រយព្រះវស្សា ។

មួយទៀត សូមផលានិសង្សនេះបង្ហូរនូវសេចក្តីសុខចំរើនគ្រប់ប្រការដល់ជនរួមជាតិក្នុងព្រះរាជអាណាចក្រ ហើយសូមឲ្យប្រទេសកម្ពុជាបានឯករាជ្យបរិបូណ៌ ក្នុងពេលយ៉ាងខ្លីកុំបីឃ្លៀងឃ្លាតឡើយ ។

ចប់


សូមកុំភ្លេច !

ទស្សនាវដ្តីកម្ពុជសុរិយានេះ ជាសម្បត្តិរបស់លោក-អ្នកហើយ, ដូច្នេះ សូមលោក-អ្នកកុំភ្លេចជួយផ្សាយដល់ជនរួមជាតិដែលនៅជិតខាង ឲ្យបានជាវទស្សនាវដ្តីនេះអានផង ព្រោះទស្សនាវដ្តីដែលនឹងមានអាយុវែង ហើយចំរើនធំធាត់ទៅបាន ដោយសារតែមានអ្នកជាវច្រើនឡើងៗ ។

សូមអរគុណ !

ព. ស. ៥